DMC ឌីអឹមស៊ីផូស
DMC Post

2025




# CAN GENERATIVE AI HELP MAKE US HAPPY?

Young Cambodians are turning to chatbots for comfort, but can AI replace human therapy?

STORIES OF HERITAGE
RESILIENCE
AND RENEWAL

www.dmcmedialab.com/dmcpost

# អារម្ភកថា

សួស្តីមិត្តអ្នកអាន!

ខ្ញុំមានក្តីសោមនស្សក្រៃលែង ក្នុងការនាំយកមកជូន ទស្សនាវដ្តីឌីអឹមស៊ីផុស ឆ្នាំ២០២៥ ដែលជាការបោះពុម្ពផ្សាយរបស់ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ (DMC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ទស្សនាវដ្តីអនទ្បាញនេះ គឺជាសមិទ្ធផលថ្មីមួយទៀត ដែលបន្តឆ្លុះបញ្ចាំងពីកម្មវិធីសិក្សាទាំងមូលរបស់ DMC ដោយផ្តោតសំខាន់លើការស្រាវជ្រាវ និងការអនុវត្តផ្ទាល់ បន្ថែមលើការសិក្សាទ្រឹស្តីនៅក្នុងថ្នាក់រៀន ដើម្បីពង្រឹងគុណភាពអប់រំឱ្យកាន់តែមានភាពពាក់ព័ន្ធ និងនវានុវត្តន៍។

មាតិការឿង និងរូបភាពនៅក្នុងទស្សនាវដ្តីនេះ គឺជាស្នាដៃការងាររបស់និស្សិតឆ្នាំទី២ នៃមុខវិជ្ជា រាយការណ៍ព័ត៌មាន និងសរសេររឿង។ នៅក្នុងការសិក្សារយៈពេលមួយឆ្នាំ ពួកគេទទួលបាននូវទ្រឹស្តីអំពីការប្រមូលព័ត៌មាន របៀបសរសេរដំណឹង និងរបៀបនិទានរឿងផ្អែកលើអង្គហេតុ (facts) អមជាមួយការចុះអនុវត្តផ្ទាល់ក្នុងការសរសេររឿងអំពីបញ្ហាបច្ចុប្បន្នភាព និងតួអង្គដែលពួកគេចាត់ទុកថាមានតម្លៃព័ត៌មានគួរលើកយកមកសរសេរប្រាប់មិត្តអ្នកអាន។ ក្នុងនោះ ក្រុមនិស្សិតបានផ្តោតលើរឿងរ៉ាវសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ បរិស្ថាន សិល្បៈ វប្បធម៌ ក៏ដូចជារឿងរ៉ាវសង្គមផ្សេងទៀតផងដែរ។ អត្ថបទរឿងមួយចំនួនក៏ត្រូវបានចុះផ្សាយនៅលើគេហទំព័របួបណ្តាយសង្គមរបស់ស្ថាប័នព័ត៌មានដៃគូរបស់យើងដូចជា គិរីផុស និងខេមបូចា រួចមកហើយនាពេលកន្លងមក។

យើងខ្ញុំត្រៀមខ្លួនជានិច្ចនឹងទទួលយកនូវមតិតបទាំងឡាយពីសំណាក់មិត្តអ្នកអាន សម្រាប់យកទៅកែលម្អទស្សនាវដ្តីនេះ នៅលេខក្រោយទៀត។

សូមរីករាយជាមួយទស្សនាវដ្តីរបស់យើង!

សូមអរគុណ!

**អ៊ុង ប៊ុនអ៊ី**

*ប្រធានដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍*

DMC Post is an online magazine published by the Department of Media and Communication (DMC) of the Royal University of Phnom Penh.

This 2025 edition represents the DMC's genuine commitment to strengthening its education quality by providing relevant and innovative learning experiences with a focus on theory, research, and practice. The year-two students carefully produce all the stories and photographs in this magazine as class assignments for the 'News Writing and Reporting' class. During their academic year, students learned news-gathering techniques, news writing skills, and fact-based storytelling, followed by practical experience reporting on current issues or stories they believe are worth covering. In this edition, students focus on issues related to development, environment, culture and arts, and other social issues. Some stories have been published by our partners' news institutions, including Kiripost and CamboJA.

We welcome reader comments to improve the quality of future editions.

**Ung Bun Y**

*Head of the Department of Media and Communication (DMC)*

# កំណត់ហេតុនិពន្ធ

ទស្សនាវដ្ដីអនឡាញ DMC Post លើកនេះ នាំមកជូនមិត្តអ្នកអាននូវរឿងថ្មីៗ ដែលផលិតដោយនិស្សិតជំនាន់ទី ២៣ នៃមុខវិជ្ជាយកព័ត៌មាន និងសរសេររឿងកម្រិត២ (NRW II) ឆ្នាំ២០២៥។ តាមរយៈការងារជាក្រុម រឿងទាំងនេះតំណាងឱ្យស្នាដៃល្អបំផុត ក្នុងចំណោមអត្ថបទកិច្ចការទាំងអស់ នៅលើប្រធានបទជាច្រើនដែលនិស្សិតផ្ដួចផ្ដើមគំនិតធ្វើដោយខ្លួនឯងផ្ទាល់។ អត្ថបទនីមួយៗបានឆ្លងកាត់ការកែសម្រួលយ៉ាងម៉ត់ចត់ ដើម្បីបំពេញតាមស្ដង់ដាខ្ពស់នៃភាពត្រឹមត្រូវ យុត្តិធម៌ និងភាពមិនលំអៀង។ អត្ថបទរឿងត្រូវបានចុះផ្សាយជាភាសាដើមដែលអ្នកនិពន្ធបានប្រើនៅក្នុងការសរសេរ គឺភាសាខ្មែរ និងអង់គ្លេស។ ការធ្វើបែបនេះ គឺដើម្បីចៀសវាងការបកស្រាយណាមួយខុសពីអង្គហេតុ និងសម្រង់សម្ដីដើម ដោយសារការបកប្រែពីភាសាមួយទៅភាសាមួយទៀត។ គួរកត់សម្គាល់ផងដែរថា អត្ថបទរឿងទាំងនេះត្រូវបានធ្វើសេចក្ដីរាយការណ៍ និងសរសេរក្នុងអំឡុងខែឧសភា ដល់ខែសីហា នៅពេលដែលថ្នាក់ NRW II កំពុងដំណើរការ។ ដូច្នេះ ខ្លឹមសាររួមការសរសេរ និងរូបភាព ឆ្លុះបញ្ចាំងអំពីស្ថានភាពនៅក្នុងក្របខណ្ឌពេលវេលានោះ បើទុកជាទិដ្ឋភាពមួយចំនួនទាក់ទងនឹងអង្គហេតុ ព័ត៌មានលម្អិត និងបញ្ហានានាដែលបានលើកឡើង អាចមានការវិវត្តប្រែប្រួលចាប់តាំងពីពេលនោះមក ក៏ដោយ។

**កែ មុនធិត**

*គ្រូឧទ្ទេស*

This edition of DMC Post offers you a new set of feature stories produced by Batch 23 students in the News Reporting and Writing II (NRW II) class, 2025. The products of teamwork, these stories represent the best among all the submissions covering a range of topics picked by the students themselves. A vigorous editing was applied to ensure that they meet a high standard of accuracy, fairness, and impartiality. The stories are published in the original languages – Khmer and English – they were written in so as to avoid any misinterpretation of facts and quotes, if they were translated into one of the two languages. It shall be noted also that these stories were reported and written during the May-August period when the NRW II class was in session. Therefore, they should be viewed and treated within this timeframe, even though certain aspects pertaining to the facts, details, and issues covered in them may have evolved since then.

**Ker Munthit**

*Lecturer*

# មាតិកា


1 Chaktomuk walk street – a step toward a greener Phnom Penh

2 Nostalgia for Phochentong Airport as Cambodia begins a new era of air travel

3 អភិរក្សសត្វផ្សោត លើកស្ទួយជីវភាព របស់សហគមន៍

4 Five years on, Chhem Sreykea remains steadfast in taking her ‘reading gardens’ across

5 ចំណេះដឹងផ្នែកបច្ចេកវិទ្យា នៅតែជាបញ្ហាប្រឈមសម្រាប់និស្សិតមកពីទីជនបទ






ឌីអឹមស៊ីផុស
DMC Post


6 Healing through technology: how Cambodian youth turn to AI for mental health support

7 នៅខេត្តសៀមរាប នារីប្រជែងជាមួយបុរសក្នុងរបររបើករ៉ឺម៉កដឹកភ្ញៀវទេសចរទៅមើលប្រាសាទ

8 នៅកំពង់ហ្លួង សិប្បកម្មធ្វើប្រាក់ និងស្ពាន់កំពុងត្រដររស់

9 នៅស្រុកបាទី មុខរបរតម្បាញហូលខ្មែរសម្លឹងទៅអនាគតដែលគ្មានអ្នកបន្តវេន

10 Cat Café: A Place Where Stray Cats Get a Second Chance at Life




ក្រុមនិស្សិត
ជំនាន់ទី ២៣

# ក្រុមការងារ


រៀបចំដោយ៖
លោក កែ មុនផិត

សម្របសម្រួលដោយ៖
លោក រ៉ូ គីមឡុង

អត្ថបទដោយ៖
តិច សុខគីម, ង៉ូវ ផីឃី
ហ៊ាន ចន្ទ្រា, មុំ សុវិទ្យា
សៀក មីហួយ, ឃុត ពិសី
ជីម ឆៃលន់, ជី ថានីត
កែវ រតនា, ម៉ុន ដាណេ
រិន សុបញ្ញា, តុង ឆេងហុង
ថាត ម៉ូលីកា, ផល្លី ស្រីនិច
ជា សុខហេង, ឃី សុទ្ធារ័ត្ន
ស៊ីម សុភ័ត្រា, ស៊ាងលី លីហួយ
ណាន់ ម៉េងហ័រ, ទូច សុវ៉ាន់យ៉ា
ហេង ហេរីន, វិទ្ធា ហាន់ហ្សា
ហេង ពេជ្រពិសិទ្ធិ, ភក្តិ សុភា

រចនាដោយ៖
ជា សុខហេង និង ឃី សុទ្ធារ័ត្ន


Chaktomuk walk



# Chaktomuk walk street – a step toward a greener Phnom Penh

***By Tech Sokkim and Ngov Pheiyi***

**Phnom Penh –** As the sun disappeared below the horizon, the familiar noise of car engines and honking horns is replaced by the lively buzz of conversation and laughter, the aroma of sizzling street food, and the sound of music and footsteps along the two-kilometer riverside road.

Welcome to the Chaktomuk walk street – a bold urban project that is quickly becoming a beloved public space in the heart of Phnom Penh.

Launched as a pilot project on February 1, 2025, the Chaktomuk walk street extends along Preah Sisowath Quay from the old post office to the Royal Palace. On every weekend from 6 p.m. to 11 p.m., the street is closed to all vehicles and accessible to pedestrians only. The project is part of a broader vision to promote much-needed green and public spaces and livability in the fast-growing city with more than 2.5 million people.

Ms. Cheng Lichhai, from Sangkat Stung Meanchey and visiting the walk street for the first time, said: "It's peaceful and not chaotic like usual traffic. I really enjoy the space."

Her friend, Ms. Seang Vanhua, a regular visitor, says she often comes here to de-stress after a tiring week of work and study. "It helps clear my mind. I like sitting here, people-watching, just relaxing."

As night falls, vendors, food and souvenir stalls get into action. The smell of grilled meats and sweet treats fills the air mixed with the sound of music and performances to cheer up visitors.

Shauna, a visitor from Ireland, was drawn in by the crowd and energy. "It's vibrant, clean, and I love trying the local food. My favorite so far is lort cha, it's amazing," she said. She pointed out the language barrier she was experiencing but said it didn't prevent her from having a good time. "Not many people speak English here, and Khmer is a hard language to learn, so I use Google Translate a lot. But it's a minor issue, the experience is still fantastic," she said.

***A Boost for Small Businesses***

Ms. Dao Samphors, spokesperson for the Phnom Penh Municipal Administration, said that, since its opening, the walk street receives an average of 80,000 to 100,000 visitors - both locals and foreign tourists on every weekend.

Although it becomes pedestrian-only path for 10 hours in the evening of Saturday and Sunday, the absence of cars and motorcycles mean a boon to small businesses.

"Sales are better here, especially when I get a good spot. But competition is high, and sometimes we're pushed to less visible areas," said Chhim Srey Pov, who sells handmade accessories.

Ms. Ouch Chenda, a Khmer noodle (num banhjok) seller, said is very happy with the introduction of the street walk as it helps small vendors like her earn more income to support their families.

"Every day I sell (num banhjok) at Psar Kandal, but on the weekends like this the volume of my sale is higher and I can earn between 300,000 and 400,000 riels (per evening), if it doesn't rain," she said.

Mr. Kao Hung operates a fruit juice card on the river bank opposite the Royal Palace. He said he usually sells between 30 and 40 glasses of juice per day from Monday to Friday, "but on Saturday and Sunday, I can sell a little over 100 glasses."

Ms. Hay Povthawin, a second-year student from the National University of Management, has recently set up a drink stall nearby, making the best use of her weekends to earn money to support her study.

"From Monday to Friday, I am busy studying and taking care of other tasks. On weekends, I try to make some money because, first, I love business, second, I want to gain experience and income to support my studies," she said.

Mr. Kuoch Veng Srun, who visited walk street for the first time one weekend in July, said he was so impressed by the atmosphere. "I see the vendors having fun, interacting with the public and making profits. I am very happy with the way the vendors are able to make their sales attractive," he said.

Busking is a rare scene in Cambodia, but the Chaktomuk walk street has provided new opportunities for artists like Mr. Khim Sokhon Bunheng to display their talents in the open - and to make the atmosphere even more festive.




*Cambodian, some with pets, take a stroll on the walk street after the rain. Photo by Chea Sokheng*

"I have been performing here since it was opened," said Mr. Sokhon, who was wearing a Khmer palm hat and kramar, with a guitar slinging on his shoulder. "On the first day, I was shaking, scared and happy, but I managed. Then, people started coming to listen to me little by little until I got a lot of support," he added.

***Unpleasant sight***

The popularity of the walk street, meanwhile, has also created sanitation challenges. Vendors, sanitation crews, and city officials said they do their best to keep the venue clean but that it's hard to keep up with the plastic waste and food leftovers that visitors littered about instead of putting them in the garbage bins.

Mr. San Narith, deputy director of public order at Khan Daun Penh, acknowledged the increase in the amount of waste as a result of the increase in number of vendors and visitors. But he added that the local authority is actively addressing the issue by enforcing the instruction for both the vendors and visitors to discard waste in the bins. "When the bins are full, teams of sanitation workers take them away continuously. There's usually no waste left by morning," he said.



Mr. Sao Hor, a 50-year-old sanitation worker, appealed to visitors for cooperation in preserving the environment along the walk street.

"We start at 6 or 7 a.m. and sometimes work until 10 p.m. on weekends. There's so much garbage. We can't even count how many bags we collect," said Mr. Sao Hor, a 50-year-old sanitation worker.

"I would like to ask all the people who come to have fun to help maintain cleanliness, like helping us. If I have to clean it alone, it's difficult," he said. "Help us by disposing of the waste properly and being responsible together, that's enough to keep the walk street beautiful."

Ms. Ser Chanpholyka, a 26-year-old juice seller, said she always follows the city instruction on sanitation management. "I always organize my garbage myself. I sweep, collect it, and throw it in the bin. And when visitors ask for trash bag, I would give it to them so that they won't litter," she said. She added that she makes sure to clean the area around he stall before she closes to go home.



*Cambodian artists perform a traditional dace to entertain revelers on the walk street. Photo by Chea Sokheng*

### *A Step Toward a Greener Phnom Penh*

Beyond the festivities and sanitation challenges, walk street symbolizes an urban planning vision that prioritizes livability and wellness of Phnom Penh's inhabitants. The city has experienced a remarkable transformation thanks largely to the sustained economic growth Cambodia had enjoyed before the pandemic struck. The economy has recovered since then, and the city's skyline keeps adding more high-rise buildings to meet the demand of a new lifestyle. At the ground level, however, the growing number of privately-owned vehicles is worsening the congestion. Meanwhile, the presence of public and green spaces serving the needs of the inhabitants remain limited.

According to a World Health Organization's 2016 report, green spaces have many public health benefits, such as mental relaxation and stress reduction, increased physical activity, and reduced impacts from air pollution, extreme heat, and noise, as well as other harmful factors in the urban environment. Every city, according to the report, should have at least 9 square meters of green space per person, which is an important source of air and oxygen.

But Phnom Penh provides less than one square meter of public space per person, according to the UNDP's 'Transforming Urban Mobility in Phnom Penh' report in 2021. The report also said public space in the capital has decreased from 1.1 square meters per person in 2014 to 0.67 square meters per person in 2020. It is lower than in other cities in the Asia-Pacific region. Singapore, on average, has 7.04 square meters of public space per person, Seoul has 14.66 square meters per person, Ho Chi Minh City has 13.7 square meters per person, and Bangkok has about 7 square meters. The report also noted that, currently, most sidewalks in Phnom Penh are used primarily for parking and business activities. It called for a strong emphasis on "walkability," pedestrian infrastructure, and reclaiming public spaces to create a positive and refreshing environment for the city inhabitants.

During the inauguration of the Morodok Techo flyover in April, Prime Minister Hun Manet said the government has allocated about 70 hectares of land in the Kob Srov for developing a public park for Phnom Penh in the future.

"In the future, the center of large cities must have large public squares, large open spaces for our citizens. And in some provinces, some cities, I suggest setting aside 100-200 hectares to be reserved as a public park for them (citizens)," the prime minister said, anticipating growth of the cities in the future. "So, reserve the land to develop public squares for the benefit of the people," he added.

Mr. Try Thoun, a professor at the Royal University of Phnom Penh, said projects like the riverfront walk street are essential in shaping healthier, more connected urban environments.

"Public spaces like this one are essential for people's sense of connection within the city," he said. "They create opportunities for social interaction and share creation, especially important in a city where such spaces are limited."

Reclaiming streets for pedestrians isn't just about recreation, but it's about equity and access, he said.

"Not everyone can afford to visit malls or cafés. Free, open areas like walking street offer a welcome environment where people from different backgrounds can gather without pressure to spend," he said.

He believes that the increase in pedestrian areas will also help raise environmental awareness among the city dwellers. "When people enjoy the city free from traffic noise and pollution, even for a short time, they begin to imagine other possibilities for urban living," Prof. Try Thoun said.

By reclaiming a portion of the riverside road for pedestrians, Phnom Penh city offers not just a lively social atmosphere but also a model for environmentally conscious urban planning. It's a small step, yet it represents a future where nature, people, and culture are at the center of city life.

Mr. Savan Sing lives in Sangkat Chbar Ampov, one of the crowded sections in Phnom Penh. As he was taking a stroll among the crowd at Chaktomuk walk street one weekend's evening, he said he considered the initiative vital for mental recharge.

"We work from Monday to Friday [and sometimes] on the weekends, so we need a space like this - a place to breathe and feel safe," he said.




*Phnom Penh International Airport. Photo: Mom Sovithyea*

# Nostalgia for Phochentong Airport as Cambodia begins a new era of air travel

***By Horn Chantra and Mom Sovithyea***

**PHNOM PENH –** After nearly seven decades of serving as the country's main gateway, Phnom Penh International Airport - Cambodia's first and oldest airport - is bidding farewell to the world, paving the way for a bigger and more modern one.

If all goes as planned, the Techo International Airport - located to the south of the capital, Phnom Penh, and about 20 kilometres from the city center - will begin operations on September 9, 2025, ushering in a new era of air travel that the government hopes will help boost further the country's development and tourism.

"If we take a look back at the Pochentong International Airport when it was operated in the Sungkum Reastr Niyum period, it played a crucial part in Cambodia's growth, especially during the late 1950s and the early 1960s, by contributing to the country's infrastructure," said Keo Duong, a history lecturer at the Royal University of Phnom Penh.

Inaugurated in 1959, Phnom Penh International Airport - known to the locals as Pochentong Airport - has witnessed up-and-down moments throughout the country's history since independence from France six years earlier. It hosted visits by several high-profile world leaders, such as French President Charles de Gaulle, who visited Cambodia in 1966, followed by Singapore's Prime Minister Lee Kuan Yew in 1967.

Seav Sapphire, now 78, recalled the festivity when he joined thousands of Cambodians in welcoming the arrival of the French president at the airport gate.

"I was 19. That day was unforgettable for me - the city was full of excitement. There was a warm welcome for General Charles de Gaulle. The scene was incredible. I remember that around 200,000 people stood along the road from Pochentong Street all the way to the Royal Palace," said Sapphire, a retiree.

***From turbulence to revival***

As the country began sliding into a civil war in 1970, the airport's roles were also transformed to serve aircrafts that were delivering U.S. economic and military aid to prop up Lon Nol's Khmer Republic regime fighting a losing battle as the Khmer Rouge rebels were closing in.

After the Khmer Rouge took power in April 1975, the airport became a witness to one of the bloody episodes during that era. According to historical accounts, Cambodian students who were studying abroad would arrive by plane after believing the Khmer Rouge's propaganda to return home to help rebuild the country after the war. As soon as they set foot on the tarmac, they

were taken away to never be seen or heard of again. Once in a while, the airport would receive flights carrying visitors from countries the Khmer Rouge had ties with at the time.

During the 1980s, as Cambodia was struggling to rebuild from ashes while being surrounded by international sanctions imposed by the West, the Pochentong airport came back to life – but with limitations – to serve airlines mostly from the Soviet bloc. One of them was Aeroflot airline that was regularly transporting Cambodian students to study in the former Soviet Union and back home after they graduated.

The airport became a scene of jubilee and hope when, on November 14, 1991, then-Prince Norodom Sihanouk returned from exile following the signing of the Paris Peace Accord on October 23 of that year. The airport's revival began to gather pace with the successive arrival of planes carrying UNTAC personnel and peacekeepers and of commercial flights, connecting Cambodia to the world once again after many years of devastating isolation.

Recognizing the potential of aviation, the Cambodian government signed an agreement with a French-Malaysia joint venture Société Concessionaire d'Aéroport (SCA), in July 1995, granting it the right to operate and upgrade the airport.

"In 30 years, it (SCA) developed the (Phnom Penh International) airport to multiply traffic by 20, from 300,000 passengers in 1995 to 6 million as of today," the company said in a statement marking the 30th anniversary of its operation of the airport in July this year.

***A new era brings mixed emotions***

According to a notice from the State Secretariat for Civil Aviation (SSCA), Techo International Airport will begin operations on September 9, 2025. It is not clear yet what the future will hold for the current airport after that date. Meanwhile, Prime Minister Hun Manetwas quick to shoot down rumors that it might become a prime property up for sale.

"There's never been a decision to sell this airport, and there won't be one," he said in a speech during a ceremony marking the 80th anniversary of the establishment of the National Police on May 16. He stressed that the airport land will remain state-owned and that final decision will be announced at the formal inauguration of Techo International Airport at a later date.




*A China Southern Airlines plane lands at Phnom Penh International Airport. Photo by Horn Chantra*

As travelers come and go, the residential areas around the Phnom Penh airport have also gradually transformed. More roads have been built and connectivity has been improved. Local businesses have sprung up to serve the growing community. For the residents, this has brought new hope and opportunity.

“The infrastructure in the community near the airport has improved a lot,” said Mach, a resident living near the airport. “I’ve been living here since 1979, when I was just a kid. It feels kind of melancholic to know that it’s going to close in a few months.”

“I’ve been selling drinks and snacks here for about five years now, and it’s really helped support me and my family,” said Kosal, a 45-year-old street vendor near the airport’s exit gate.

“It’s sad to know I won’t be able to run this small business here anymore after it closes,” he said, adding that he would have to take his business somewhere to earn a living.

Sim Chanchakriya, a 22-year-old resident who used to enjoy the extra lights beamed from the airport over her neighborhood near it, said: “I can’t imagine how dark my house will be when the airport stops operating, because the airport lights always shine toward my house at night—this is so sad to even think about it.”



# អភិរក្សសត្វផ្សោតលើកស្ទួយជីវភាពរបស់សហគមន៍

*ដោយ សៀក ម៉ីហួយ និង យុត ពិសី*

**ក្រចេះ –** ក្នុងរវាងពីរទៅបីវិនាទីម្តង សត្វផ្សោតមួយក្រុមឆ្លាស់វេនគ្នាលេចក្បាលនៅលើផ្ទៃទឹកនៅអន្លង់ផ្សោតកាំពី នៃទន្លេមេគង្គ។ មួយមុជក្បាលចុះ មួយទៀតលេចក្បាលឡើង បញ្ចេញសូរដកដង្ហើមដែលបំបែកភាពស្ងប់ស្ងាត់នៅលើផ្ទៃទឹក និងហាក់បីដូចជាឱ្យសញ្ញាថា ពួកវាសុខសប្បាយទេ។

ជាងបីឆ្នាំក្រោយពីមានការស្លាប់ច្រើនក្បាល សត្វផ្សោតមានចំនួនកើនឡើងជាលំដាប់ ផ្តល់ពន្លឺក្តីសង្ឃឹមឡើងវិញសម្រាប់អនាគតរបស់សត្វកម្រមួយនេះ និងសម្រាប់អ្នកស្រុកក្រីក្រ ដែលធ្លាប់តែពឹងផ្អែកលើរបរនេសាទដើម្បីចិញ្ចឹមជីវិត។

“ពីមុនយើងអត់មានអី យើងរកតែត្រី តាំងពីមានការធ្វើរូបចម្លាក់មក យើងរកបានចំណូលពីរូបចម្លាក់សត្វផ្សោត ចឹងអាចជួយបានច្រើន ដែលជាហេតុធ្វើឱ្យប្រជាជននៅទីនេះធូរធារជាងមុន ដែលពីមុនយើងរកតែត្រី រកបានព្រឹក ខ្វះល្ងាច” - នេះជាប្រសាសន៍របស់ លោកស្រី ឈាង វីណា អ្នករស់នៅតំបន់រមណីយដ្ឋានអន្លង់ផ្សោតកាំពី ក្នុង ខេត្តក្រចេះ។

ណាវី នៅចាំ កាលពីប៉ុន្មានឆ្នាំមុន អំពីកង្វល់នៅពេលណាគាត់ឮដំណឹងថាមានសត្វផ្សោតស្លាប់ម្តងៗ ដោយនិយាយថា៖ “ខ្ញុំមានការភ័យបារម្ភ ព្រោះអីសត្វផ្សោតជាសត្វដែលអាចទាក់ទាញភ្ញៀវទេសចរ ដើម្បីជួយដល់ប្រជាជនយើងក្នុងការកស៊ីផងដែរ”។

រមណីយដ្ឋានអន្លង់ផ្សោតកាំពី ជាតំបន់អភិរក្សសត្វផ្សោតតាមដងទន្លេមេគង្គមួយ មានចម្ងាយប្រមាណជា ១៥ គីឡូម៉ែត្រ ពីក្រុងក្រចេះ។ យោងតាមអង្គការមូលនិធិសត្វព្រៃពិភពលោក (World Wildlife Fund) ផ្សោត ឈ្មោះជាភាសាអង់គ្លេសថា Irrawaddy Dolphin ជាប្រភេទសត្វថនិកសត្វដ៏កម្រ ដែលមានតែនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងឥណ្ឌូណេស៊ីប៉ុណ្ណោះ ក្រៅពីប្រទេសកម្ពុជា។ វាត្រូវបានចាត់ទុកថាកំពុងប្រឈមគ្រោះថ្នាក់ខ្លាំង នៅក្នុងបញ្ជី



*មេផ្សោត និងកូនរបស់វាកំពុងហែលនៅក្នុងតំបន់អភិរក្សអន្លង់ផ្សោតកាំពី ទន្លេមេគង្គ ខេត្តក្រចេះ។ រូបថតដោយ៖ ឃុត ពិសី*

ក្រហមនៃសត្វរងការគំរាមកំហែង របស់អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (International Union for Conservation of Nature/IUCN)។ សកម្មភាពនេសាទខុសច្បាប់ និងការបំពុលបរិស្ថាន ដូចជាសំរាមថង់ប្លាស្ទិក ត្រូវបានគេដឹងថាជាមូលហេតុចម្បងធ្វើឱ្យសត្វនេះស្លាប់ គួបផ្សំនឹងការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលរបបទឹកដោយសារការសាងសង់ទំនប់វារីអគ្គិសនីនាប៉ែកខាងលើនៃទន្លេមេគង្គ ដែលប៉ះពាល់ដល់ទីជម្រកធម្មជាតិសម្រាប់រស់រាន និងការបន្តពូជរបស់វា។

នៅក្នុងឆ្នាំ២០២២ សត្វនេះបានស្លាប់ច្រើន រហូតដល់ទៅ ១១ក្បាល ក្នុងនោះចំនួន៣ក្បាលស្លាប់បន្តគ្នាក្នុងខែធ្នូតែមួយ ដោយសារជាប់ជំពាក់មងរបស់អ្នកនេសាទ ដែលជាសញ្ញាអាសន្នតម្រូវឱ្យចាត់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ការវិនាសរបស់វា។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ រាជរដ្ឋាភិបាលចេញអនុក្រឹត្យមួយកំណត់តំបន់គ្រប់គ្រង និងអភិរក្សសត្វផ្សោតក្នុងទន្លេមេគង្គ ប្រវែង ១២០គីឡូម៉ែត្រ - ៣៥គីឡូម៉ែត្រនៅក្នុងខេត្តស្ទឹងត្រែង និង ៨៥គីឡូម៉ែត្រនៅក្នុងខេត្តក្រចេះ - គិតជាផ្ទៃសរុបមាន ១២៤២គីឡូម៉ែត្រក្រឡា។ ការនេសាទត្រីនៅក្នុងតំបន់នេះត្រូវបានហាមឃាត់ស្ទើរតែទាំងស្រុង ជាពិសេសការនេសាទដោយប្រើមង ឬសន្ទូចរនង និងឧបករណ៍ខ្នាតមធ្យម និងខ្នាតធំផ្សេងទៀត។ ការធ្វើនាវាចរក្នុងល្បឿនលើសពី ៣០គីឡូម៉ែត្រក្នុងមួយម៉ោងត្រូវបានហាមឃាត់, ទូកមានឧបករណ៍នេសាទហាមឆ្លងកាត់ ហើយការតាំងលំនៅក៏មិនត្រូវឱ្យមានដែរ នៅក្នុងតំបន់អភិរក្ស ដើម្បីបញ្ចៀស "ផលប៉ះពាល់ដល់ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ ជាពិសេសសត្វផ្សោត ដែលជារតនសម្បត្តិ ធម្មជាតិមានជីវិតដ៏ពិសិដ្ឋ" របស់កម្ពុជា។

ចាប់តាំងពីពេលនោះមក វត្តមានរបស់សត្វផ្សោតបានកើនឡើងបន្តិចម្តងៗ ហើយគិតត្រឹមខែឧសភាឆ្នាំ២០២៥ វាមានចំនួនសរុប ១១១ក្បាល ជាចំនួនខ្ពស់ជាងគេ បើគិតពីឆ្នាំ២០២១ ដោយមិនទាន់ មានស្លាប់ មួយនៅឡើយទេ។

លោក នុត ឫទ្ធី មន្ត្រីខណ្ឌរដ្ឋបាលជលផលខេត្តក្រចេះ និងប្រធានឆ្នាំប៉ុស្តិ៍អន្លង់កាំពី មានប្រសាសន៍ថា វិធានការតាមរយៈអនុក្រឹត្យឆ្នាំ២០២៣ បានធ្វើឱ្យសកម្មភាពខុសច្បាប់ ថយចុះច្រើននៅក្នុងតំបន់អភិរក្សសត្វផ្សោត។ ប៉ុន្តែលោកបានពោលបន្ថែមទៀតថា ទោះបីជាមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ការពារខ្លាំងយ៉ាងណាក៏ដោយ ក៏នៅមានជនឆ្លៀតឱកាសប្រព្រឹត្តបទល្មើសខុសច្បាប់ដែរក្នុងពីរឆ្នាំចុងក្រោយនេះ។ លោកមានប្រសាសន៍ថា៖ "យើងចាប់បានជនសង្ស័យ ហើយយើងបានបញ្ជូនទៅតុលាការជាច្រើននាក់ដែរហើយ"។

## ***ទាក់ទាញទេសចរណ៍***

លោក អោក ដារុណ អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ និយាយថា ការអភិរក្សសត្វ ផ្សោតមានសារៈសំខាន់ខ្លាំងសម្រាប់ការរស់រានរបស់សត្វដ៏កម្រមួយនេះ ដែលជា ចំណុចទាក់ទាញមួយផ្នែក ទេសចរណ៍ នាំមកនូវការផ្លាស់ប្តូរមុខមាត់របស់សហគមន៍កាំពីបានប្រសើរឡើងជាងមុនច្រើន។ លោកពោលថា៖ "តាំងពីបង្កើតសហគមន៍កាំពីនេះមក ទីមួយគឺការបង្កើតមុខរបរថ្មីដែលនាំឱ្យពួកគាត់ធ្វើរូបចម្លាក់ផ្សោតចម្លាក់ផ្សេងៗ ដើម្បីលក់នៅតំបន់ទេសចរណ៍អន្លង់កាំពី អ៊ីចឹងជីវភាពរបស់ពួកគាត់ប្រែប្រួលច្រើន ជាពិសេសតំបន់ផ្សោត គាត់អាចចែវទូក លក់វត្ថុអនុស្សាវរីយ៍ ហើយមួយផ្នែកទៀតគឺគាត់ជួលតូបដើម្បីធ្វើសេវាកម្មផ្សេងៗ"។

លោក ទុយ សុវណ្ណា ប្រធានសហគមន៍កាំពី និយាយថា សឹងតែ ៨០ភាគរយ នៃប្រជាពលរដ្ឋរស់នៅតំបន់នោះបានផ្លាស់ប្តូរមុខរបរ



ភ្ញៀវទេសចរជិះទូកមើលសត្វផ្សោតនៅអន្លង់កាំពី ទន្លេមេគង្គ ខេត្តក្រចេះ។ រូបថតដោយ៖ ឃុត ពិសី

ពីអ្នកនេសាទត្រី មកជាអ្នកប្រកបអាជីវកម្មផ្សេងៗនៅក្នុងតំបន់ទេសចរណ៍មួយនេះ ដោយសារតែសត្វផ្សោត។ “កាលពី១០ឆ្នាំមុន យើងធ្លាប់តែមានផ្ទះតូចៗ មួយៗ តែឥឡូវនេះ អ្នកមកក្រោយទៀតមកមើលលែង ចង់ស្គាល់ព្រោះប្រែប្រួលច្រើន ដោយសារតែវិស័យទេសចរណ៍នឹងហើយ”។

មន្ទីរទេសចរណ៍ខេត្តបានឱ្យដឹងថា គិតត្រឹមខែមេសា ឆ្នាំ២០២៥ ខេត្តទទួលបានទេសចរចំនួន ៤២៨ ៨៨៣នាក់ គឺច្រើនជាងពីរដង បើធៀបទៅនឹងចំនួន ១៩២ ០៣៧នាក់ ក្នុងឆ្នាំ២០២២។

លោក ប្រាក់ វិបុល ប្រធានការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ខេត្តក្រចេះ និយាយថា កាលណា មាន សត្វផ្សោតស្លាប់ វាអាចជះផលមិនល្អទៅលើផ្នែកទេសចរណ៍ដែរ ព្រោះ “ភ្ញៀវទេសចរបរទេសរំពឹង មកមើល ចង់ឃើញសត្វផ្សោតហ្នឹងហើយ ដែលហៅបានថាជារបស់កម្រ ជាសត្វមួយដែលជាសម្បត្តិបេតិកភណ្ឌជាតិ”។ លោកពោល ទៀតថា តាមធម្មតា ភ្ញៀវទេសចរអន្តរជាតិមកទស្សនាសត្វផ្សោត ច្រើនជាងភ្ញៀវទេសចរជាតិ ដែលពុំសូវមានចំណាប់អារម្មណ៍ទៅមើលរមណីយដ្ឋានអន្លង់ផ្សោតកាំពី ទេ។

លោក សរ ម៉ុល ស្ថិតនៅក្នុងចំណោមភ្ញៀវទេសចរជាតិដែលបានទៅលេងនៅរមណីយដ្ឋានអន្លង់កាំពី កាលពីពេលថ្មីៗនេះ។ លោកបាននាំសមាជិកគ្រួសារជាច្រើននាក់មកមកពីខេត្តកំពង់ធំ ហើយសម្រាប់លោកផ្ទាល់ គឺជាលើកដំបូងហើយដែលបានឃើញសត្វផ្សោតផ្ទាល់ភ្នែក។ លោកមានប្រសាសន៍ដូច្នេះថា៖ “តាំងពីខ្ញុំនៅតូចរហូតដល់អាយុដល់ ៥០ជាងហើយ ទើបបានឃើញសត្វផ្សោតច្បាស់ៗ លើកទីមួយ។ ការអភិរក្សរបស់គេល្អ ព្រមទាំងសំណូមពរឱ្យប្រជាជនខ្មែរទាំងអស់មកទស្សនាសត្វផ្សោតឱ្យបានច្រើន”។



លោក ច្រឹក សុធា ដែលជាភ្ញៀវទេសចរជាតិបាននិយាយថា៖ “ខ្ញុំមានអារម្មណ៍ប្លែកនៅពេលបានឃើញសត្វផ្សោត ដោយសារយើងអត់ដែរបានមកទេ។ ហើយមានអារម្មណ៍ថាល្អ ដែលយើងអាចអភិរក្សបានចឹង ដើម្បីទុកឱ្យកូនចៅនៅប្រទេសកម្ពុជាយើង ឱ្យភ្ញៀវទេសចរមកលេងកាន់តែច្រើន”។

សម្រាប់លោក Ciarán ភ្ញៀវទេសចរមកពីប្រទេសអៀរឡង់ សត្វផ្សោតគឺជាគោលដៅមួយដែលគាត់មិនអាចរំលងបាននៅក្នុងកម្មវិធីដើរកម្សាន្តរបស់គាត់នៅប្រទេសកម្ពុជា។ លោកនិយាយដូច្នេះថា៖ “ខ្ញុំបានធ្វើដំណើរកំសាន្តជុំវិញប្រទេសកម្ពុជាអស់រយៈពេល ពីរ-បី សប្តាហ៍ ហើយខ្ញុំពិតជាចង់ឃើញភាពស្រស់ស្អាត និងភាពទាក់ទាញរបស់សត្វផ្សោតណាស់។ ខ្ញុំជ្រើសរើសការជិះកាយ៉ាក់ ដើម្បីគយគន់ និងទស្សនាសត្វផ្សោត វាពិតជាមានភាពស្រស់ស្អាត និងអស្ចារ្យមែនទែន”។

លោក កែប សុហ៊ាង អ្នកបើកទូកដឹកភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋានកាំពី បង្ហាញក្តីសង្ឃឹមថា ពីនេះតទៅ ចំនួនសត្វផ្សោតនឹងកើនកាន់តែច្រើន ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ឆ្នាំក្នុងការល្បាតនៅក្នុងតំបន់ការពារ និងអភិរក្សសត្វផ្សោត។

“កាលណាបាត់បង់ផ្សោត យើងក៏បាត់ការងារដូចគ្នា” - លោកនិយាយដូច្នេះ ហើយបន្តទៀតថា៖ “តំបន់ទេសចរណ៍នេះបានផ្តល់ឱ្យខ្ញុំមានចំណូលចិញ្ចឹមគ្រួសារ ទោះបីជាថ្ងៃខ្លះបានតិច តែក៏មានថ្ងៃខ្លះក៏បានលុយច្រើនដែរ អ៊ីចឹងយើងអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានសមរម្យ”។

“បើសិនជាអត់សហគមន៍នេះ យើងមានតែចំណាកពីភូមិនេះទៅទីក្រុង ធ្វើសំណង់ ឬធ្វើអីតាម ដែលយើង អាចរកបានធ្វើ។ តែបើមានផ្សោតកាន់តែច្រើន ភ្ញៀវកាន់តែច្រើន ធ្វើឱ្យខ្ញុំមានចំណូលកាន់តែច្រើន អ៊ីចឹង ខ្ញុំសង្ឃឹមថ្ងៃមុខទៀត ផ្សោតកាន់តែកើនឡើងទៀត ហើយចង់បានឱ្យភ្ញៀវមកកាន់តែច្រើនទៀត”។

លោក អោក ដារុណ អនុប្រធានមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ បានធ្វើការសង្កត់ធ្ងន់ថា ការចូលរួមរបស់ប្រជាពលរដ្ឋនិងអ្នកពាក់ពន្ធទាំងអស់ជាមួយអាជ្ញាធរមានសមត្ថកិច្ច មានសារៈសំខាន់ណាស់ ដើម្បីការរស់រាន និងរីកចម្រើនរបស់សត្វផ្សោតយូរអង្វែងទៅមុខ ពីព្រោះ “សត្វផ្សោតគឺជាសម្បត្តិរួម” របស់ខ្មែរទាំងអស់គ្នា៕



*A young Cambodian man reads a book at a park in Phnom Penh. Photo by Chhem Sreykea*

# Cheem Sreykea on a mission to revive reading habit among Cambodians

***By Chim Chhailun and Chy Thanith***

**Phnom Penh –** In an era where digital access brings daily life both convenience and distraction, keeping a book reading habit has proven to be an uphill battle among Cambodians. But Chhem Sreykea, a university student, is on a mission to help her fellow citizens rediscover the joy of reading books.

For the past five years, 24-year-old Sreykea, who described herself as a bookworm, has been busy promoting reading among Cambodians, especially young children, who tend to be more fixated on smart phones than books these days. She has turned public space and parks into weekend's open-air libraries where books are spread across the grass for everyone to pick up and read.

"When I was in high school, my family didn't have much money. I had to save up for a long time just to buy one book, which cost between 3,000 to 3,500 riel," recalled Sreykea, a fourth-year student at Preah Sihanouk Raja Buddhist University. "That's what inspired me to collect all the books I had and place them in a public park in Pailin. I wanted others to have easier access to books than I did," she said.

Her journey began in 2020 in Pailin province, her hometown, where she first introduced the idea of placing small-format books in public parks. The concept was simple but powerful: provide free access to books in areas where libraries were scarce or non-existent. What started as a personal initiative, fueled by a deep love for reading, quickly grew into a community-supported effort that expanded to the capital city of Phnom Penh by 2022. Now, Sreykea has set her sights on an even bigger goal to establish libraries in remote areas across all 25 provinces, capitals, and cities of Cambodia.



### *AI's impact on reading*

Speaking at the National Institute of Education in May this year, Cambodian Prime Minister Hun Manet cautioned against the negative effect that too much reliance on artificial intelligence (AI) could potentially cause to mental development, especially the ability to read.

"I've noticed people broadcasting meetings without taking any notes, just recording the audio, asking AI to summarize, and then copying it," he noted. "Over time, this habit erodes our ability to read, write, and think critically. If we depend too heavily on technology, what happens when the devices fail? We will struggle to write or summarize everything ourselves. Thinking, writing, and summarizing are essential for mental development, and relying solely on external tools poses a serious risk."

Cambodia is one of those countries where over 50% of children struggle to read or understand a simple story by the end of primary school, according to the World Bank. It said providing high-quality storybooks and engaging community members in promoting reading habits can significantly impact reading outcomes. "Improving literacy is crucial for children to succeed academically and enhance their life opportunities," it said.

The 10th National Reading Day in March this year was held under the theme "Reading connects people across generations in society." Like in previous years, it featured book fairs, reading competitions, and exhibitions with the aim to foster the reading habits and writing skills among children.

### *More mobile libraries, please!*

Khem Sokheng, a 34-year-old mother, recalled how her 14-year-old son was immediately drawn to the display of Sreykea's books during a Sunday Walk.

"I was walking along the pedestrian path on a Sunday when my child saw the book display set up by the young woman," she said. "He asked me if he could read it. My child really loves studying and books. I truly admire her for creating this mini-library. I'm very impressed with her effort [because] there aren't many people doing things like this."

Chhun Socheat, a 25-year-old architect, spoke highly of the reading areas established by Sreykea. "I stumbled upon one of her book displays, and I was truly impressed. I took some time to read, and I appreciated the selection. Her initiative is so important, especially for children. Having access to books in public spaces helps them learn, ask questions, and develop critical thinking skills."

"We need more public street libraries, not just in cities but in rural areas too. They are vital for education and community development," he added.

### *Fostering reading as community service*

Sreykea draws inspiration from practices she has observed abroad, where public reading spaces are common and highly valued. She envisions a similar culture in Cambodia, one where reading in parks, on sidewalks, or in any public setting becomes a normal and celebrated part of daily life.

"Reading is always beneficial, whether it is in a library or outdoors, but reading in public does require more patience and confidence," she said. "You are aware of the people around you, their stares, their curiosity. But that is also what makes it special, it creates a shared space for learning and reflection."

Now a fourth-year student studying Khmer literature, Sreykea balances her academic responsibilities with her reading initiatives. Her determination has not affected her academic progress either. “I manage my time well. I carry out reading activities on the weekend and visit provinces during school breaks. I can study and work remotely, so everything runs smoothly,” she said.

Unlike full-time NGOs, Sreykea and her team raise funds only when there is a specific project, such as building a new library. She clarified that she does not receive regular support from organizations or associations, making each effort a labor of love.

“We usually organize fundraising campaigns every two or three months,” she explained. “It is not something we do every day, and we do not have ongoing financial support. But we keep going because we believe in the cause.”

While she doesn’t have precise data on how many people use her “reading gardens,” she estimates a readership of around 10,000 across the provinces so far. In addition to that, two community libraries have been established in Siem Reap province and one each in Kampong Cham, Pursat, Svay Rieng, Kandal, and Battambang. She is grateful for the consistent support, but also acknowledges the skepticism that social workers and community activists often face.

“Sometimes when we raise funds for reading activities, people assume we are using the money for personal gain,” she said. “Even though we maintain transparency with a clear list of expenses, doubts still linger. It is heartbreaking. Many people see this as a business rather than a community service, which discourages participation. There are times when I have had to use my savings, working hard during school vacations, to fund these activities.”

Ray Lang, a student at the Royal University of Phnom Penh and a supporter of Sreykea’s monthly donation initiative, said she has no doubt about Sreykea’s motivation.

“I have known her since high school, and I’ve always supported her work,” Ray Lang said. “Her efforts are inspiring. She has gotten a lot of support in the provinces, and her work is encouraging more young people to read. Placing books in public spaces may seem simple, but it has a big impact.”

Looking ahead, Sreykea said she couldn’t be bothered by any skepticism and remains unwavering in her ambitious plan to promote a reading culture throughout the country. She firmly believes that reading enriches the soul, strengthens communities when it is valued and embraced by the people, and, most importantly, helps to narrow the educational gap for children in underserved areas.

“My objective is clear,” she said. “I want to build libraries across the country and encourage reading until it becomes something people do as naturally as walking or talking.”



*Children and adults gather around the books on display at a park in Phnom Penh. Photo by Chhem Sreykea*

# កង្វះចំណេះដឹងផ្នែកបច្ចេកវិទ្យា នៅតែជាបញ្ហាប្រឈមសម្រាប់និស្សិតមកពីជនបទ

### *ដោយ កែវ រតនា និង ម៉ុន ដាណេ*

**ភ្នំពេញ -** កញ្ញា ជ្រន ផាន់នី ជានិស្សិតស្លាបត្យកម្ម នៅចាំអំពីការលំបាកជាច្រើនដែលនាងបានជួបប្រទះនៅក្នុងការសិក្សា នៅពេលដែលនាងចាប់ផ្តើមចូលរៀនឆ្នាំដំបូងនៅសាកលវិទ្យាល័យមួយ នៅរាជធានីភ្នំពេញ។

នាងបាននិយាយដូច្នេះថា៖ “ដោយតែខ្ញុំអត់សូវចេះចុច typing នៅលើកុំព្យូទ័រ វាធ្វើឱ្យខ្ញុំមានការលំបាកក្នុងការធ្វើស្លាយ (slide)។ ជួនកាលកំពុងតែធ្វើ វាលោតទៅកន្លែងផ្សេង ដែលខ្ញុំអត់ចេះ ហើយប្រគល់ (Submit) ការងារសាលាឱ្យគ្រូ អត់ទាន់កាលបរិច្ឆេទ (Deadline) ក៏មានដែរ”។



*យុវតី ជ្រន ផាន់នី កំពុងតែធ្វើកិច្ចការសាលារបស់ខ្លួននៅសាកលវិទ្យាល័យន័រតុន។ រូបភាពដោយ៖ ម៉ុន ដាណេ*

ខណៈពេលដែលកម្ពុជាកំពុងបញ្ជ្រាបបច្ចេកវិទ្យាឌីជីថល និងរកវិធីបញ្ចូលបញ្ញាសិប្បនិម្មិតទៅក្នុងវិស័យអប់រំ នៅមាននិស្សិតជាច្រើនមកពីគ្រួសារដែលមិនសូវមានជីវភាពធូរធារ កំពុងត្រដាបត្រដួសនៅឡើយ ក្នុងការរត់ឱ្យទាន់និស្សិតដទៃទៀតនៅក្នុងការសិក្សាតាមបែបឌីជីថល នៅកម្រិតឧត្តមសិក្សា។

បញ្ហាប្រឈមដែលពួកគេភាគច្រើនបានជួបប្រទះ គឺ កង្វះខាតមូលដ្ឋានគ្រឹះភាសាអង់គ្លេស និងចំណេះដឹងមូលដ្ឋានក្នុងការប្រើប្រាស់កម្មវិធីនៅក្នុងកុំព្យូទ័រ ដែលជាមធ្យោបាយខ្វះមិនបានសម្រាប់ការសិក្សានៅក្នុងយុគ្គសម័យនេះ។

ជ្រួន ផាន់នី វ័យ២១ឆ្នាំ ជាកូនគ្រួសារកសិករមួយនៅក្នុងខេត្តតាកែវ ដែលកំពុងរៀនផ្នែកស្ថាបត្យកម្មនៅសាកលវិទ្យាល័យមួយ ក្នុងរាជធានីភ្នំពេញ។ នាងបានរៀបរាប់ថា ថ្វីត្បិតតែនាងធ្លាប់បានរៀនកុំព្យូទ័រនៅឯស្រុកកំណើតកន្លងមកកាលនាងមានអាយុ១៧ឆ្នាំ ក៏ដោយ ប៉ុន្តែការរៀននោះមិនបានផ្តោតសំខាន់ទៅលើមូលដ្ឋានសំខាន់ៗមួយចំនួន ដូចជា Microsoft Team ឬកម្មវិធីផ្សេងទៀតដែលអាចសម្រួលដល់ការសិក្សារបស់នាងនៅសាកលវិទ្យាល័យឡើយ។ ពោលគឺ នាងបានរៀនត្រឹមតែការវាយអក្សរ ខ្លះៗតែប៉ុណ្ណោះ។

នាងពោលទាំងទឹកមុខស្រពោនថា៖ “វាប៉ះពាល់ចិត្តដែរ ធ្វើឱ្យយើងមានអារម្មណ៍ថាខ្លួនឯងអន់ជាងគេ តូចចិត្តជាមួយខ្លួនឯងថា ម៉េចគេចេះ យើងអត់ចេះអ៊ីចឹង។ ម៉្យាងទៀត ដោយសារខ្ញុំរស់នៅតំបន់រាងដាច់ស្រយាល អ៊ីចឹងហើយសេវាអ៊ីនធឺណិតអីអត់សូវល្អទេ អត់សូវដើរខ្លាំងដូចយើងនៅទីរួមខេត្ត វាដើររាងទាក់ៗ”។

ដោយសារផ្ទះរបស់នាងនៅឆ្ងាយពីទីប្រជុំជន ផាន់នីនិយាយថា នាងរៀនភាសាអង់គ្លេសបានតិចតួចបំផុត ហើយ ឪពុកម្តាយមិនមែនជាអ្នកធូរធារ ដូច្នេះពួកគាត់គ្មានលទ្ធភាពផ្គត់ផ្គង់លុយកាក់សម្រាប់នាងទៅរៀនអង់គ្លេសនៅទីរួមខេត្ត និងទិញសម្ភារចាំបាច់ក្នុងការរៀនសូត្រតាមបែបឌីជីថល ឱ្យបានគ្រប់គ្រាន់ដែរ។

ការសិក្សាស្រាវជ្រាវមួយរបស់អង្គការយូនីស្កូទៅភលើប្រធានបទតិចណូឡូជីនៅប្រទេសកម្ពុជា (Technology In Cambodia) ដែលបានចេញផ្សាយនៅឆ្នាំ២០២៣ បានឱ្យដឹងថា កម្ពុជាមានការវិវត្តខ្លាំងខាងការអប់រំបែបឌីជីថលក្នុងកំឡុងពេលកូវីដ-១៩ ដោយមានការសិក្សាពីចម្ងាយតាមរយៈទូរទស្សន៍ ហ្វេសប៊ុក តេឡេក្រាម ការសិក្សារបស់ក្រសួងអប់រំអំពី E-learning app និង កម្មវិធីប៊ីប (BEEP Platform) ផងដែរ។ ប៉ុន្តែ របាយការណ៍នេះក៏បានបង្ហាញដែរអំពីវិសមភាពរវាងសិស្សដែលរៀនបែបឌីជីថលនៅទីក្រុង ធៀបទៅនឹងអ្នកនៅជនបទ ក្នុងនោះ ៧៨ ភាគរយ នៃសិស្សជនបទ អាចរៀនពីចម្ងាយបានតាមទូរសព្ទដៃតែប៉ុណ្ណោះ។ របាយការណ៍នេះបានឱ្យដឹងទៀតថា ផ្ទុយទៅវិញ សិស្សដែលរៀននៅទីក្រុង មានភាពងាយស្រួលជាងសិស្សនៅជនបទទាំងខាងលទ្ធភាពទទួលបានសេវាអ៊ីនធឺណិត សម្ភារអេឡិចត្រូនិចដូចជា ទូរសព្ទ និងកុំព្យូទ័រ ជាពិសេសនោះគឺហិរញ្ញវត្ថុក្នុងគ្រួសារនីមួយៗ និងចំណេះដឹងមូលដ្ឋានគ្រឹះបែបឌីជីថលផ្សេងៗទៀត។

នៅក្នុងខែកុម្ភៈ ដើមឆ្នាំនេះ កម្ពុជាបានបើកកិច្ចប្រជុំកំពូលជាលើកដំបូង ស្តីពីបច្ចេកវិទ្យាឌីជីថលនៅក្នុងវិស័យអប់រំ ឈ្មោះជាអង់គ្លេសថា EdTech Summit 2025។ ព្រឹត្តិការណ៍នេះបានសង្កត់ធ្ងន់លើតួនាទីនៃបច្ចេកវិទ្យាឌីជីថលក្នុងការពង្រឹងគុណភាព និងភាពពាក់ព័ន្ធនៃការបង្រៀន ការរៀន ភាពបរិយាបន្ន ការគ្រប់គ្រង និងអភិបាលកិច្ចអប់រំ។

ថ្លែងក្នុងពិធីនោះ ឯកឧត្តម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការរួមបញ្ចូលបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត (AI) ទៅក្នុងប្រព័ន្ធអប់រំ។ ឯកឧត្តមបានលើកឡើងពីភាពចាំបាច់រៀបចំយុវជនកម្ពុជាឱ្យមានបំណិនជីវិតថ្មីក្នុងបច្ចេកវិទ្យាឌីជីថល ដើម្បីបំពេញតម្រូវការទីផ្សារការងារនាពេលអនាគត។

“គោលដៅរបស់យើង គឺជួយសម្រួលដល់យុវជនរបស់យើងក្នុងការឈានទៅចាប់យកបំណិនជីវិតថ្មីនៅក្នុងបច្ចេកវិទ្យាឌីជីថល ជាពិសេសនៅក្នុង AI ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ” លោករដ្ឋមន្ត្រីត្រូវបានដកស្រង់ប្រសាសន៍ដូច្នេះ នៅក្នុងសារព័ត៌មាន B2B Cambodia។ លោកបានបន្ថែមទៀតថា៖ “ប្រសិនបើយុវជនរបស់យើងមិនត្រៀមខ្លួន ពួកគេនឹងមិនអាចតាមទាន់ការអភិវឌ្ឍនៃបច្ចេកវិទ្យានេះបានទេ”។

កញ្ញា ម៉ូ ស្រីនីត ជានិស្សិតវ័យ១៩ឆ្នាំ មកពីខេត្តបន្ទាយមានជ័យ ដែលកំពុងសិក្សាជំនាញអេឡិចត្រូនិចអគ្គិសនី ក្នុងសាកលវិទ្យាល័យមួយនៅក្នុងរាជធានីភ្នំពេញ បានរំឭកបទពិសោធន៍ផ្ទាល់ខ្លួនដូច្នេះថា៖ “សូម្បីតែ typing ក៏អត់ចេះដែរ ដូចមាន់ចឹកស្រូវ។ ឆ្នាំទី១ យើងត្រូវការជំនាញកុំព្យូទ័រ ដើម្បីធ្វើ slide ហើយ assignment (កិច្ចការ) យើងអាចពឹងឱ្យក្រុមយើងធ្វើបាន ប៉ុន្តែអនាគតទៅ យើងមិនប្រាកដពឹងគេឱ្យធ្វើបានទេ យើងត្រូវរៀនខ្លួនឯង”។

នាងពោលបន្តទៀតថា បញ្ហាចម្បងដែលនាងប្រឈមមុខពេលមកបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅភ្នំពេញគឺ កង្វះខាតថវិកា បញ្ហាក្នុងការប្រើប្រាស់កុំព្យូទ័រ និង ការប្រើប្រាស់ភាសាអង់គ្លេស។

នាងបានបន្តរៀបរាប់ថា កាលពីនាងសិក្សានៅថ្នាក់វិទ្យាល័យនាងមិនបានរៀនកុំព្យូទ័រក្រៅម៉ោងហើយ ថែមទាំងមិនមានលទ្ធភាពសម្រាប់ទិញកុំព្យូទ័រមកស្វ័យសិក្សាដោយខ្លួនឯងទៀត។ ប្រសិនបើនាងបានរៀនពីមូលដ្ឋានគ្រឹះនៃកុំព្យូទ័រពីមុនមក នាងពិតជានឹងមានពេលវេលាគ្រប់គ្រាន់ផ្តោតលើជំនាញគោលរបស់នាងឡើងវិញ។

***ខ្វះខ្វែងជួយគ្នា***

ដោយឃើញបញ្ហានេះ កញ្ញា សំ ស្រីនិត និស្សិតម្នាក់ទៀត បានសហការជាមួយមិត្តភក្តិបង្កើតគម្រោងមួយឈ្មោះថា STEAM in Action ដើម្បីជួយត្រៀមមូលដ្ឋានគ្រឹះផ្នែកកុំព្យូទ័រ ឌីជីថល និងភាសាអង់គ្លេស សម្រាប់សិស្សានុសិស្សពីជនបទ ឬតំបន់ដាច់ស្រយាល មកបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។

កញ្ញាបានលើកឡើងថា៖ "អ្នកដែលរៀនចប់ថ្នាក់ទី ១២ ហើយឡើងមកសិក្សានៅសាកលវិទ្យាល័យភ្នំពេញ ភាគច្រើនគ្រាន់តែដឹងពីការប្រើប្រាស់ Microsoft word, PowerPoint, documents ប៉ុន្តែជំនាញដែលលើសពីមូលដ្ឋានគ្រឹះដែលគាត់ដឹងហ្នឹង គាត់អត់សូវមានទេ ពេលដែលគាត់មករៀនសាកល ឬចង់ចាប់ជំនាញអីផ្សេងហ្នឹង គាត់តាមអត់ទាន់គេ"។ កញ្ញាបានបន្តទៀតថា៖ "អង់គ្លេសជាភាសាសំខាន់មួយ។ សម្រាប់ការរៀន STEM ឬក៏រៀនការសរសេរកូដអី ត្រូវចេះមូលដ្ឋានគ្រឹះអង់គ្លេសដែរ ... បើយើងអត់ចេះ យើងក៏តាមគេអត់ទាន់គេដែរ"។

បច្ចុប្បន្នគម្រោង STEAM in Action នេះ កំពុងសហការជាមួយសាលារៀនចំនួន ៥ មាន សាលាបឋមសិក្សាវត្តបូណ៌ ក្នុងខេត្តសៀមរាប, អនុវិទ្យាល័យអារញ្ញរាំងសីនៅខេត្តកំពង់ស្ពឺ, អនុវិទ្យាល័យពោធិ៍សាត់នៅក្នុងខេត្តពោធិ៍សាត់, វិទ្យាល័យពេជ្រចិន្ដានៅក្នុងខេត្តបាត់ដំបង, និង សាលាសហគមន៍ក្បាលព្រោះនៅក្នុងខេត្តកំពង់ស្ពឺ។

កញ្ញា យិន ស្រីណុច វ័យ២២ឆ្នាំ ជានិស្សិតទើបនឹងបញ្ចប់ការសិក្សាជំនាញ Computer Science នៅក្នុងសាកលវិទ្យាល័យរដ្ឋមួយនៅក្នុងរាជធានីភ្នំពេញ។ ជានិស្សិតមកពីជនបទនៅក្នុងខេត្តតាកែវ នាងបានចែករំលែកបទពិសោធន៍ដោយនិយាយថា៖ "បើសិនជាធ្លាប់បានរៀនពីមូលដ្ឋានគ្រឹះរបស់កុំព្យូទ័រតាំងពីវិទ្យាល័យមក ប្រហែលជាស្រួលស្រាវជ្រាវឯកសារទាក់ទងជាមួយ កិច្ចការសាលាផ្សេងៗ បានលឿនហើយងាយស្រួលទៀត អត់ចាំបាច់ចំណាយពេលយូរដូចពេលយើងអត់ទាន់ចេះទេ"។

កញ្ញាបានបន្តទៀតថា ក្រៅពីការសិក្សាពីមូលដ្ឋានគ្រឹះរបស់កុំព្យូទ័រ អ្វីដែលសំខាន់ទន្ទឹមគ្នានោះ ការចេះប្រើប្រាស់ភាសាអង់គ្លេស ព្រោះថា "បើយើងខ្សោយភាសាអង់គ្លេស គឺយើងពិបាករៀន និងរៀនយឺតជាងគេ ដោយសារយើងពិបាកធ្វើការស្រាវជ្រាវផ្សេងៗ ដែលត្រូវការពាក្យបច្ចេកទេសដើម្បីស្វែងរកប្រធាបបទមួយនឹងឱ្យឃើញ"។

នៅវិទ្យាល័យពេជ្រចិន្តា ស្ថិតនៅក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ហើយជាវិទ្យាល័យមួយដែលបានសសហការជាមួយគម្រោង STEAM in Action, លោកគ្រូ ប៉ិច ឈឿត ប្រធានគណៈនាយកសាលា មានប្រសាសន៍ថា មុខវិជ្ជាវិទ្យាសាស្ត្រមានតម្លៃណាស់ ដោយនៅពេលសិស្សចាប់យកមុខវិជ្ជានេះហើយរៀនពូកែ ពួកគេនឹងមានឱកាសចាប់មុខជំនាញជាច្រើនទៀតនៅសាកលវិទ្យាល័យ ដែលសុទ្ធសឹងតែជាមុខជំនាញមានទីផ្សារការងារល្អៗមែនទែន។

លោកគ្រូមានប្រសាសន៍ថា៖ "បំណងប្រាថ្នារបស់ខ្ញុំ គឺចង់ឱ្យសាលាក្លាយជាសាលាឌីជីថលឱ្យស្របទៅនឹងបរិបទពិភពលោកឌីជីថល។ ទោះបីសិស្សខ្ញុំ ១៤០០ នាក់ជាង បើបានត្រឹមតែ ១០០ នាក់ ក៏ចំនួនអ្នកដែលចេះបច្ចេកវិទ្យាហ្នឹង ជួយសង្គមយើងបាន១០០នាក់បាត់ហើយ"។

នៅក្រោមសំឡេងអ៊ូអរលាយឡំជាមួយក្លិនកាហ្វេឈ្ងុយៗនៅក្នុងហាងកាហ្វេមួយ លោក ហ៊ុន កាណាល់ គ្រូបង្រៀននៅដេប៉ាតឺម៉ង់គណិតវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រេបកាហ្វេបណ្ដើរ ហើយរៀបរាប់បណ្ដើរ អំពីការសង្កេតរបស់គាត់ ឆ្លងកាត់តាមការបង្រៀន លើទម្លាប់មួយដែលមិនថានិស្សិតមកពីជនបទ ឬនិស្សិតនៅទីក្រុងទេ មាននៅក្នុងការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យានៅក្នុងជីវិត និងការសិក្សារបស់ពួកគេ។

លោកនិយាយថា ការដែលសិស្សានុសិស្សមានចំណេះដឹងទាក់ទងនឹងជំនាញបច្ចេកវិទ្យាគឺពិតជាចាំបាច់ខ្លាំងមែនទែន ដោយសារសម័យកាលផ្លាស់ប្ដូរ ហើយសម្ភារនៅក្នុងការសិក្សាគឺសុទ្ធសឹងតែទាក់ទងនឹងតិចណូឡូជីស្ទើរតែទាំងអស់ទៅហើយ។ ប៉ុន្តែ តាមរយៈការសង្កេតឃើញរបស់លោក និស្សិតសឹងតែទាំងអស់ទៅហើយ មិនថានៅទីក្រុងឬជនបទទេ ដែលមានទូរសព្ទគ្រប់ៗគ្នា ច្រើនតែប្រើប្រាស់វាបែបកម្សាន្តច្រើនជាងស្វែងរកការពង្រីកចំណេះដឹង។

លោកបានបន្តថា៖ "ដោយសារឯកសារភាគច្រើនវាជាភាសាអង់គ្លេស ប្រសិនបើគាត់គ្មានចំណេះដឹងភាសាអង់គ្លេសបូករួមនឹងការដែលអត់ចេះប្រើបណ្ដាញវេបសាយមួយចំនួនដូចជា យូធូប ដែលមានភាសាប្រធានបទសំខាន់ៗ ឬ វេបសាយណាសំខាន់ៗ គាត់អត់ចេះភាសាអង់គ្លេស គឺគាត់អត់អាចទៅប្រើប្រាស់ឱ្យមានប្រសិទ្ធភាពបានទេ"។

ជាមួយនឹងការលុកលុយពេញទំហឹងរបស់បញ្ញាសិប្បនិម្មិតនាពេលបច្ចុប្បន្ន លោក ហ៊ុន កាណាល់ មានប្រសាសន៍ក្នុងន័យដាស់តឿនឱ្យមានការប្រុងប្រយ័ត្នថា៖ "AI ដូចយើងធ្លាប់បានដឹងវាដូចជាឌិសថ អាវុធមុខពីរ ប្រសិនបើយើងចេះប្រើវា នោះវាមានអត្ថប្រយោជន៍ច្រើន ប៉ុន្តែប្រសិនបើយើងអត់ចេះប្រើ វាអាចធ្វើអោយប៉ះពាល់ដល់ការដំណើរ ដល់ការរៀនសូត្ររបស់យើងដែរ"៕

# Healing through technology: how Cambodian youth turn to AI for mental health support

***By Rin Sokpanha and Tong Chhenghong***

**Phnom Penh –** Panha recalled how she was regularly bullied by her classmates when she was in high school. Gradually, she developed a mental issue but it didn't catch her family's attention.

"They bullied me in both real life and online until I fell into the lowest point of wanting to commit suicide," said Voleakpanha, now a third-year student at Royal University of Phnom Penh.

She said she couldn't muster enough courage to reach out to her family and friends for help until one day she found a remedy – Artificial Intelligence (AI).

AI is rapidly becoming both essential and widely used across the globe, with many people relying on it to handle various tasks. But when it comes to something as personal and complex as mental health, can AI offer effective support?




*Panha, a university student, chats with ChatGPT to seek advise on mental health issues. Photo by: Tong Chhenghong*

According to the World Happiness Report 2024, Cambodia has been ranked as the unhappiest country in the Southeast Asia region while having the highest percentage of the population with poor mental health.

A report by the Ministry of Health stated that mental health concerns in Cambodia have soared to approximately 282,615 cases reported in 2024, showing an increase of nearly 200% from 2023. The report added that the number of patients receiving treatments increased by 28.52% compared to the same period in 2023.

Mr. Nou Channan, a psychologist at Sombok Psychology – a psychology practice in Phnom Penh where qualified team of Cambodian and expatriates offer professional psychological services – observed that many young people aged 18 to 20 commonly struggle with mental challenges such as depression, anxiety, and stress. He also explained that mental illnesses are diagnosed conditions in which individuals experience specific, persistent symptoms that impact their daily functioning.

***Why AI?***

Panha said she would talk to ChatGPT three to four times a week whenever she feels triggered and lonely and had no one to talk to.

"After talking to AI, I feel peaceful, calmer, and better. Sometimes, I turn the conversion into something interesting," she said. But it can help her just in a short time and not last long.

She used to talk to BetterHelp, an online platform that helps you connect with real therapist from everywhere in the world that best fit with the patients. However, she has switched to AI instead because the professional service is too expensive.

"I met them two times a week [and paid] 60 dollars for each session. For some people, 120 dollars equals their monthly salary," she said.

Vivath Fortune, a student of the Department of English and International Business Management, recalls a time when she felt "uneasy and



*Panha, a university student, chats with ChatGPT to seek advise on mental health issues. Photo by: Tong Chhenghong*

emotionally tangled," yet didn't believe she had a mental health issue that necessitated professional help.

"I didn't think that I had any mental issues to begin with," Fortune explains. "It was just a phase of feelings and uneasiness in my body. Whenever I felt like I didn't want to tell anybody about it, I would just message AI and read advice for a bit and then move on."

Like many young generations in Cambodia, Fortune underwent many emotional fluctuations. Tools like ChatGPT and Poe have become her confidential companions.

When asked why she chose AI over a human therapist, Fortune said: "To be honest, I didn't think I would need a therapist. Therapy is not accessible really; it's costly."

Sarin Ritika, a 21-year-old university student at the Royal University of Phnom Penh (RUPP) and English at the Institute of Foreign Languages, openly shared how the COVID-19 pandemic shaped her struggles.

During quarantine, emotional numbness became her norm. "Sometimes I'd feel everything at once, and other times I'd feel nothing at all," she recalled. "It was exhausting, even scary. I didn't even notice how silent I had become until my aunt said she was happy [that] I was finally talking again."

Despite having access to free counselling at her university, Ritika hesitated to seek help. "Even though I study psychology, and my classmates encouraged me to try therapy, I just wasn't comfortable opening up to a real person," she admitted.

Instead, she turned to Character. AI. "This app has lots of bots where you can make up a scenario or just talk to them as a friend. They have different roles," said Ritika.

"With AI, I feel safe. They just follow your prompts. Sometimes, that's exactly what I need," she said. "I feel like I'm not judged when I'm with them because they're just programmed. I don't see them as human. And you know, humans have emotions, like judging is just a part of

human nature, so, yeah, that's why I chose AI instead," she added.

Young Cambodians interviewed for this article cited a combination of family tensions, personal challenges, work-related issues, academic pressure, social status, financial instability, and concerns about job prospects as factors affecting their mental health.

Heng Sopanha, a software development student, recalled how DeepSeek played a role in his journey toward healing of mental health problems he has suffered primarily due to family issues and academic pressures.

"I use DeepSeek because it listens without criticizing me," said Sopanha, 20. He added that social media platforms like Facebook and TikTok can also contribute to mental health struggles through bullying and constant comparison. "Seeing what others achieve and wanting to be like them affect users negatively," he said.

***AI or professional therapist?***

The expansion of AI as a form of emotional support has sparked debate. Is it a helpful first step or a risky replacement for human interaction?

Mr. Pov Phannet, a lecturer and researcher on AI at the Cambodia Academy of Digital Technology (CADT), explained that information on chatbots always gives general answers depending on the training data without a specific domain, so it is quite inaccurate for an individual's situation. Moreover, because of that, AI does not always give the positive answers that one might have expected.

Mrs. Thoun Sreypov, a student counsellor, said AI cannot replace human professional therapists.

"AI cannot analyse some complex problems that happen to individuals. For instance, young people who face family violence cannot just use AI. Case like this must be addressed by professional therapists, including their own families, to stop that action," she added.

***Seeking help is a strength, not weakness***

Mr. Nou Channan, the psychologist at Sombok Psychology, explained AI cannot diagnose the level of mental health of individuals. He acknowledges that therapy sometimes can be costly depending on the standard, the degree, and the policy each institution or company has set.

Likewise, he added, it depends on the level of the patient's illness. The more serious, the more expensive, like physical illness. Some institutions get funds from the government or a partnership organization, so they can provide free treatment, he said

Mr. Channan noticed the common misconception among some individuals who view seeking psychological support as a sign of weakness or mental instability. He said such a view is completely incorrect, adding that mental health is an essential aspect of overall well-being that deserves the same attention as physical health.

"When people experience physical illness or symptoms, they promptly consult a doctor and follow prescribed treatments. However, society often unfairly labels the expression of emotional distress as 'crazy'," he explained.

"Seeking help is a human's strength, not weakness," Mr. Channan.

"We call it self-love or self-compassion because they [affected persons] sometimes focus on others rather than themselves," Channan said. "All individuals' life journeys have these experiences, but if we are in that situation, will we want to move on or not? If you want [to move on], you need to change the way you think."

He suggested those experiencing difficult emotional states to not rely too much on AI as a healing companion and "to seek help from your friends, family, teacher, or someone you trust" instead.

Sarin Ritika, the RUPP psychology student, called for a shift in attitudes especially among older generation to be more open-minded and to not overlook mental health issues affecting young people in their families.

Making therapy more accessible and affordable and greater awareness campaigns will be useful to help people open up instead of keeping everything to themselves, said Vivath Fortune, the English and business management student.

Heng Sopanha, the software development student, said that, without adequate attention and action to address it, mental illness could have major implications for the country's development in the future. "If we lose more human resource to mental issues, our country's economy and development will decline day by day," he said.



អ្នកស្រី មុត ដឿន ជាអ្នករត់រ៉ឺម៉កម៉ូតូកង់បី នៅខេត្តសៀមរាប។ រូបភាពដោយ៖ ផល្លី ស្រីនិច

# នៅខេត្តសៀមរាប នារីកាន់តែច្រើនបើករ៉ឺម៉កដឹកភ្ញៀវទេសចរទៅមើលប្រាសាទ

***ដោយ ចាត ម៉ូលីកា និង ផល្លី ស្រីនិច***

**សៀមរាប -** ជារៀងរាល់ព្រឹក អ្នកស្រី មុត ដឿន ជួយស្វាមីរបស់គាត់រៀបចំកន្លែងលក់កាហ្វេរបស់គាត់ដែលនៅក្បែរដងស្ទឹងសៀមរាបសិន មុននឹងបើករ៉ឺម៉កម៉ូតូទៅយកភ្ញៀវទេសចរទៅមើលប្រាសាទ។ ដូចអ្នកស្រុកឯទៀតនៅក្នុងខេត្តដែលពឹងលើវិស័យទេសចរណ៍ មុត ដឿន បានបាត់បង់ការងារជាចុងភៅនៅក្នុងហាងអ៊ីតាលីមួយកាលពីសម័យកូវីដ-១៩ ហើយបានមកដល់ជាចំណុចរបត់មួយនៃផ្លូវជីវិត ដោយក្លាយខ្លួនជាអ្នកបើករ៉ឺម៉កប្រជែងជាមួយបុរសក្នុងការដឹកភ្ញៀវទេសចរ ដើម្បីរកចំណូលចិញ្ចឹមគ្រួសារ។

“ពេលខ្ញុំមកដឹកភ្ញៀវ ប្ដីនៅផ្ទះគាត់នៅលក់ ហើយមើលកូន ប៉ុន្តែលក់តែមួយព្រឹកៗទេ ចឹងហើយគាត់នៅផ្ទះមើលកូន ជូនកូនទៅរៀននិងធ្វើម្ហូបជូនអ្នកផ្ទះ” - អ្នកស្រី មុត ដឿន អាយុ ៣២ឆ្នាំ ដែលប្រកបរបរនេះមកបានរយៈពេល ១ឆ្នាំហើយនោះ។

នៅក្រុងសៀមរាប មានស្ត្រី ៥០នាក់ជាង ជាអ្នកបើករ៉ឺម៉កដឹកភ្ញៀវទេសចរ ដែលកន្លងមកច្រើនមានតែបុរសទេដែលផ្ដាច់មុខនៅក្នុងមុខរបរមួយនេះ។ ពួកគេបានចងក្រងគ្នាជាក្រុមមួយ ក្រោមគំនិតផ្តួចផ្តើមរបស់អ្នកស្រី គីម សុខលាង - គេហៅជាទូទៅថា បង គីម - អាយុ ៣៨ឆ្នាំ និងជាប្រធានសមាគមអ្នកបើករ៉ឺម៉កទេសចរសៀមរាប។

ដើមឡើយ បង គីម ជាអ្នកលក់ត្រីនៅក្នុងផ្សារច្បារអំពៅនៅភ្នំពេញទេ ប៉ុន្តែគាត់បានប្តូររបរមកធ្វើជាអ្នករត់រ៉ឺម៉កវិញ ដើម្បីអាចជូនកូនប្រុសដែលមានពិការភាព គ ថ្លង់ ទៅរៀន។ ផ្តើមមុខរបរថ្មីដំបូងនៅឆ្នាំ២០១៣ បង គីម បានធ្វើឱ្យមនុស្សជាច្រើនមានចម្ងល់ថាហេតុអ្វីស្ត្រីមកបើករ៉ឺម៉ក ហើយដោយសារមិនសូវមានម៉ូយជិះ គាត់ក៏សម្រេចចិត្តផ្លាស់ទីលំនៅមកប្រកបរបរមួយនេះនៅក្នុងខេត្តសៀមរាប នៅចុងឆ្នាំ២០១៤ វិញ។

បង គីម មានប្រសាសន៍ថា៖ “កាលពីដំបូងដែលខ្ញុំចាប់ផ្តើម គ្មានអ្នកជឿថាយើងជាអ្នករត់រ៉ឺម៉កទេ មនុស្សទាំងអស់សុទ្ធតែមិនសូវគាំទ្រព្រោះគិតថាវាមិនអាចទៅរួច។ខ្ញុំគ្រាន់ចង់បង្ហាញគាត់ថាមនុស្សទាំងអស់សុទ្ធតែធ្វើការងារបានដូចគ្នា ហើយខ្ញុំនឹងធ្វើឱ្យមើលប៉ុណ្ណឹងឯង”។

ការចាប់ផ្តើមថ្មី ផ្តល់ឱកាសថ្មីឱ្យបងគីម បញ្ចេញសមត្ថភាពរបស់ខ្លួននៅលើទឹកដីខេត្តមួយសម្បូរទៅដោយប្រាសាទបុរាណដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក និងជាគោលដៅធំជាងគេសម្រាប់ភ្ញៀវទេសចរបរទេសដែលមកលេងប្រទេសកម្ពុជា។ បន្តិចម្តងៗ សេវាបើករ៉ឺម៉កដឹកភ្ញៀវរបស់បងគីម បានធ្វើឱ្យទេសចរ

ពេញចិត្ត និងសរសើរជាច្រើន កេរ្តិ៍ឈ្មោះល្អរបស់គាត់កាន់តែសុសសាយ រកចំណូលបានជាប្រចាំរហូតដល់អាចសន្សំបានយកទៅទិញដី និងសាងសង់ផ្ទះ ដែលគាត់កំពុងរស់នៅបច្ចុប្បន្ន និងធ្វើជាស្នាក់ការសមាគមអ្នកបើករ៉ឺម៉កទេសចរសៀមរាប ទៀតផង។

បងគីម បានពោលថា៖ "ខ្ញុំចិញ្ចឹមគំនិតចង់បង្កើតសមាគមតាំងពីខ្ញុំកាន់ដៃចង្កូត (រ៉ឺម៉ក) ដំបូងនៅរាជធានីភ្នំពេញម្ល៉េះ"។ ប៉ុន្តែដោយសារយើងគ្មានការិយាល័យគ្មានអី កាលនឹងយើងនៅផ្ទះជួលដល់ចឹងទៅយើងអត់មានសមត្ថភាពបង្កើតសមាគមទេ ដល់ខ្ញុំមកសៀមរាបខ្ញុំសន្សំលុយទិញបានដីមួយកន្លែងខ្ញុំក៏ចាប់ផ្តើមបង្កើតសមាគម"។

មកទល់ពេលនេះស្ត្រីដែលប្រកបរបរជា អ្នកបើករ៉ឺម៉កទេសចរនៅក្រុងសៀមរាបបានទទួលការបង្ហាត់បង្រៀនបើករ៉ឺម៉ក ដើម្បីបង្កើនលទ្ធភាពក្នុងការប្រកបរបរទ្រទ្រង់គ្រួសារ។ ក្រោយពីទទួលការហ្វឹកហាត់រួច ភាគច្រើនបានចេញទៅធ្វើជាអ្នកបើករ៉ឺម៉កឯករាជ្យ ហើយបច្ចុប្បន្ននៅសល់ស្ត្រី ១០នាក់ ដែលសមាជិករបស់សមាគម។ ពួកគេតែងជួយគ្នាក្នុងការចែកភ្ញៀវឱ្យគ្នាដឹកតាមដែលអាចធ្វើទៅបានដើម្បីប្រាកដថា គ្រប់គ្នានៅក្នុងក្រុមអាចរកប្រាក់ចំណូលបានជាប្រចាំថ្ងៃ។ បងគីម និយាយថា៖ "សមាគមរាដូចជាថ្នាក់រៀនចឹង យើងមើលថាអ្នកណាចង់ grow up (លូតលាស់) មុនគេ ខ្ញុំតែងតែផ្តល់ភ្ញៀវឯកជនខ្ញុំមួយឱ្យមុនគេ។"

ម្នាក់ៗសុទ្ធតែយកចិត្តទុកដាក់ក្នុងការបម្រើសេវា ដោយរ៉ឺម៉កនីមួយមានទឹកសុទ្ធ ក្រមា កន្សែងត្រជាក់ សម្រាប់ភ្ញៀវទេសចរដែលជួលពួកគាត់ឱ្យដឹកទៅមើលប្រាសាទ និងសហគមន៍ជនបទ។

### ***ពីចុងភៅហាងអ៊ីតាលីមករត់រ៉ឺម៉ក***

មុត ដឿន ធ្លាប់ធ្វើចុងភៅនៅក្នុងភោជនីយដ្ឋានអ៊ីតាលីមួយក្នុងក្រុងសៀមរាប។ ប៉ុន្តែ ដូចអ្នកស្រុកឯទៀតនៅក្នុងខេត្តសៀមរាបដែលពឹងលើទេសចរណ៍ ជីវភាពរបស់គ្រួសារគាត់ត្រូវធ្លាក់ចុះក្នុងភាពលំបាក នៅពេលជំងឺរាតត្បាតកូវីដ-១៩វាយលុកនៅដើមឆ្នាំ២០២០។ ដោយសារអត់មានទេសចរទៅសៀមរាប ហាងអ៊ីតាលីនោះត្រូវបិទទ្វារជាបណ្តោះអាសន្នដែលធ្វើឲ្យ មុត ដឿន ក៏លែងមានការងារធ្វើដែរ។ គាត់បានងាកមកបើកតូបលក់កាហ្វេនៅក្នុងភូមិដើម្បីរកប្រាក់ជួយទប់គ្នាជាមួយប្តីរបស់គាត់ ដែលជាអ្នកបើករ៉ឺម៉កដែរ ប៉ុន្តែរកចំណូលមិនសូវបានដោយសារពេលនោះអត់សូវមានភ្ញៀវទៅសៀមរាប។ ជាជម្រើសចុងក្រោយ មុត ដឿន សម្រេចចិត្តធ្វើជាអ្នកបើករ៉ឺម៉កវិញ តាមការណែនាំរបស់ស្ត្រីជិតខាងដែលជាអ្នករត់រ៉ឺម៉ក់ដូចគ្នា ហើយសំខាន់ដោយឃើញ បងគីម ជាគំរូជំរុញទឹកចិត្ត។

មុត ដឿន បានពោលថា៖ "ជាដំបូងឡើយខ្ញុំគិតថាបងគីមគាត់អាចជួយស្រីៗបានច្រើន បើយើងរត់ខ្លួនឯង ទីមួយយើងអត់មានបទពិសោធភាសាយើងក៏អត់សូវពូកែ ចឹងបើចូលជាមួយបងគីមគាត់ជួយបង្រៀនយើងបានច្រើន ណែនាំយើងឱ្យភ្ញៀវ គាត់ជាមេដ៏ល្អមួយដឹកនាំយើងឱ្យគេស្គាល់"។

### ***ស្ទារឡើងវិញក្រោយកូវីដ***

ឧស្សាហកម្មទេសចរណ៍នៅសៀមរាប បានងើបឡើងវិញបន្តិចម្តងៗក្រោយពីរងការខូចខាតយ៉ាងដំណំ ដោយសារការរាតត្បាតជំងឺកូវីដ-១៩។ តាមការចុះផ្សាយរបស់ក្រសួងព័ត៌មាន នៅក្នុងឆមាសទី១ នៃដើមឆ្នាំ២០២៥នេះ ខេត្តសៀមរាបទទួលបានភ្ញៀវទេសចរប្រមាណ២ ៨៩៣ ០០៨នាក់ ចំនួននេះបង្ហាញអំពីការកើនឡើង ៥០,៩១ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ក្នុងនោះមានភ្ញៀវទេសចរជាតិចំនួន ២ ៣២៥ ៣៣៥នាក់ កើនឡើង ៦៦,៦៨ភាគរយ និងភ្ញៀវអន្តរជាត់រួមមាន ៥៦៧ ៦៧៣នាក់ មានភាពកើនឡើង ៨,៧៦ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ។

បើទុកជាមានភាពប្រសើរឡើងបន្តិចក្តី ទាំងអាជីវករទូទៅ ទាំងអ្នករត់រ៉ឺម៉ក នៅតែថ្ងូរថាពិបាករកចំណូល មិនដូចកាលនៅមុនសម័យកូវីដ។

"តាំងពីកូវីដមករាពិបាក និយាយឱ្យចំបាត់អស់ ៧០ ទៅ ៨០ភាគរយ យើងបានចំណូលបានតែ ២០ភាគរយបើធៀបនឹងមុនកូវីដ" - លោក ប៉ិច ស៊ីវ ដែលជាអ្នករត់រ៉ឺម៉កទេសចរជិត ២០ឆ្នាំហើយ មានប្រសាសន៍ដូច្នេះ។ លោកក៏បានបញ្ជាក់បន្ថែមទៀតថា ការធ្លាក់ចុះចំណូលនេះមិនមែនមកពីមិនសូវមានភ្ញៀវមកតែមួយមុខនោះទេ ប៉ុន្តែដោយសារមានការប្រកួតប្រជែងខ្លាំងនៅពេលមានអ្នកបើកបរដឹកភ្ញៀវច្រើនជាងមុន ជាពិសេសការជ្រៀតចូលរបស់អ្នកបើកបរដែលប្រើ ផាស់អាប់ (PassApp) និង ហ្គ្រេប (Grab)។

លោក ស៊ាន សង អ្នកបើករ៉ឺម៉កទេសចរម្នាក់ទៀត មានប្រសាសន៍ថា៖ "យើង តាំងពីក្រោយកូវីដ បើប្រៀបធៀបវាខុសគ្នាឆ្ងាយពីមុនកូវីដ ពីព្រោះអី ពីប្រទេសមួយទៅប្រទេសមួយ វាមានបញ្ហាគ្រប់តែប្រទេសនឹង ភ្ញៀវគាត់អត់សូវ traveling (ធ្វើដំណើរ) ច្រើនហើយប្រទេសយើងវាជាប្រទេសតូចមួយទៀតវាអត់សូវមកដល់តែម្តង ហើយចាប់ពីកូវីដមកគឺឱ្យត់តែម្តងភ្ញៀវ"។

បង គីម ក៏យល់ស្របដូចគេដែរ ត្រង់ចំណុចនេះ។ ក្នុងនាមជាប្រធានសមាគម គាត់ចង់ឱ្យរដ្ឋាភិបាលជួយរៀបចំបង្កើននូវហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែប្រសើរជាងមុន ដូចជាការបង្កើតនូវភូមិខ្មែរ តំបន់អាហារខ្មែរ ការជិះទស្សនាប្រាសាទដោយរ៉ឺម៉កដើម្បីជួយទាក់ទាញភ្ញៀវទេសចរមកឱ្យកាន់តែច្រើន។ បង គីម ពោលដូច្នេះថា៖ "មានប្រាសាទអង្គរវត្តពិតមែនតែខ្វះទំនាក់ទំនងបដិសណ្ឋារកិច្ចល្អ ចឹងទាល់តែយើងសហការគ្នា"។

លោក កែវ សំអាត បើករ៉ឺម៉កអស់រយៈពេលជិត ១០ឆ្នាំ មកហើយ យល់ស្របថា ការសហការគឺជារឿងសំខាន់សម្រាប់អ្នកប្រកបអាជីពដូចគ្នា មិនថាបុរស ឬ ស្ត្រីទេ។ អំពីអ្នកស្ត្រីបើករ៉ឺម៉ក គាត់ពោលដូច្នេះថា៖ “ខ្ញុំថាវាមិនជាខុសគ្នាទេ ព្រោះថាគាត់មានកម្លាំងស្មើនឹងយើងដែរ គាត់ក៏អាចទទួលការងារនឹងបានឱ្យតែគាត់ពេញចិត្តធ្វើទីមួយ, ទីពីរគាត់អាចជួយរកចំណូលគ្រួសារគាត់ ជួនកាលមិនមែនតែគាត់ទេ ប្តីគាត់ក៏រត់ដែរ (ស្ត្រីខ្លះ) ប្តីគាត់អូសទាញឱ្យមកធ្វើការងារនឹង”។

ខុសពីរ៉ឺម៉ករបស់ប្រុសៗ រ៉ឺម៉ករបស់ស្ត្រីមានការតុបតែងលម្អជាមួយផ្កាឈូកស្រស់ជារៀងរាល់ថ្ងៃ សម្រាប់ទាក់ទាញការចាប់អារម្មណ៍ពីសំណាក់ភ្ញៀវបរទេស ភាគច្រើនមកពីខាងអឺរ៉ុប។ នៅក្នុងធ្វើដំណើរតាមរ៉ឺម៉កទៅមើលប្រាសាទ ភ្ញៀវទទួលបានក្រមាជាវត្ថុស្វាគមន៍ ទឹកសុទ្ធសម្រាប់ជូនភ្ញៀវពិសា កន្ទ្រេងត្រជាក់សម្រាប់ជូតទប់នឹងអាកាសធាតុក្តៅ។

ប្តីរបស់អ្នកស្រី មុត ដឿន ក៏ជាអ្នករត់រ៉ឺម៉កដូចគ្នាដែរ ហើយគាត់ទាំងពីរឆ្លាស់វេនគ្នាដើម្បីមើលថែកូន ២នាក់ និងធ្វើការងារផ្ទះដោយមិនមានការប្រកាន់ការងារប្រុសឬការងារស្រីនៅក្នុងផ្ទះឡើយ។ ថ្ងៃណាដែលជាវេនរបស់គាត់ចេញទៅដឹកភ្ញៀវ បង មុត ដឿន នាំចូលផ្ទះវិញនូវចំណូល ៧ ទៅ ៨ម៉ឺន រៀល មិនទាន់រាប់ចូលធីប ខណៈប្តីរកបានខ្លះទៀតពីការរត់រ៉ឺម៉ក ឬលក់កាហ្វេនៅផ្ទះ។

អ្វីដែលនៅពិបាក “គឺភាសាអង់គ្លេសយើងអត់សូវចេះ” - បង មុត ដឿន និយាយដូច្នេះ ដោយសន្យាថានឹងព្យាយាមរៀនភាសានេះឱ្យកាន់តែស្ទាត់ ដើម្បីអាចសន្ទនាជាមួយភ្ញៀវឱ្យបានកាន់តែប្រសើរឡើង។ គាត់ពោលបន្ថែមទៀតថា៖ “មុខរបរនឹងវាមានន័យសម្រាប់ខ្ញុំ ខ្ញុំមានមោទនភាពនៅពេលដែលបានជូនភ្ញៀវទេសចរឱ្យបានស្គាល់ពីប្រទេសយើង។ យើងមានអារម្មណ៍ថាមានមោទនភាពណាស់៕




*អ្នកស្រី មុត ដឿន ជាអ្នករត់រម៉កម៉ូតូកង់បី នៅខេត្តសៀមរាប។ រូបភាពដោយ៖ ផល្លី ស្រីនិច*

# នៅកំពង់ហ្លួង សិប្បកម្មធ្វើប្រាក់ និងស្ពាន់កំពុងត្រដររស់

*ដោយ ជា សុខហេង និង យី សុទ្ធារ័ត្ន*



*ការឆ្លាក់ចម្លាក់ក្នុងរឿងរាមកេរ្តិ៍លើផ្ទិល ក្នុងភូមិពរទូច ខេត្តកណ្តាល។ រូបភាពដោយ៖ ជា សុខហេង*



**កណ្ដាល -** ពេលចូលដល់ក្នុងភូមិពោធិ៍តូច ឃុំកំពង់ហ្លួង ស្រុកពញាឮ កាលមុនគេធ្លាប់តែឮសំឡេងដំលោហវត្ថុលាន់កងរំពងពេញភូមិមួយនេះ ដែលស្ថិតនៅខេត្តកណ្ដាល ខាងជើងរាជធានីភ្នំពេញ។ ប៉ុន្តែ សព្វថ្ងៃនេះ សំឡេង តុប-តាក់ តុប-តាក់ លាន់ឡើងយូរៗម្ដងចេញពីផ្ទះអ្នកស្រុកមួយចំនួនតូចដែលនៅប្រកបរបរដាប់ឆ្លាក់ប្រាក់ និងស្ពាន់ ហើយអំពាវនាវរកការគាំទ្រដល់សិប្បកម្មបែបប្រពៃណី ដែលមានអាយុកាលរាប់រយឆ្នាំមកហើយ។

“សិប្បករភាគច្រើនជាមនុស្សចាស់ មានយុវជនតិចតួចណាស់ដែលជ្រើសរើសបន្តរបរប្រពៃណីនេះ” - អ្នកស្រី ជុំ បុប្ផា មានប្រសាសន៍ដូច្នេះខណៈដែលដៃរបស់គាត់ទាំងពីរកំពុងរវល់ដាប់ឆ្លាក់វត្ថុសិល្បៈមួយដែលជាផ្ទិលប្រាក់និងមានក្បាច់ផ្កាពីលើនៅមុខផ្ទះសិប្បកម្មរបស់គាត់។

តាំងពីសម័យលង្វែកមក ភូមិនេះ ដែលស្ថិតក្នុងឃុំកំពង់ហ្លួងល្បីឈ្មោះខាងផលិតគ្រឿងអលង្ការ ចម្លាក់ និងវត្ថុផ្សេងៗពីប្រាក់និងស្ពាន់យ៉ាងសម្បូរបែប។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៦០ សិប្បករនៅទីនោះមានប្រមាណ ៦០០គ្រួសារ ប៉ុន្តែសព្វថ្ងៃនៅសល់តែ ៣៧គ្រួសារ ប៉ុណ្ណោះ ដែលនៅប្រកបមុខរបរមួយនេះ។

សិប្បកម្មធ្វើប្រាក់ និងស្ពាន់នៅកំពង់ហ្លួង មានឫសគល់ពីរឿងព្រេងមួយ ដែលអ្នកភូមិបានតំណាលតៗគ្នា ថា កាលនៅសម័យបន្ទាយលង្វែក មានជាងដែកម្នាក់បានចាកចេញពីវាំង ហើយធ្វើដំណើរទៅដល់ភូមិពោធិ៍តូច នៅទីនោះគាត់បានជួប និងលង់ស្នេហ៍ជាមួយនារីក្នុងស្រុកម្នាក់។ បន្ទាប់ពីរៀបការរួច គាត់បានតាំងទីលំនៅក្នុងភូមិនោះ ហើយបានប្រកបរបរចម្លាក់ប្រាក់ និងស្ពាន់ក្នុងផ្ទះស្វាត់ជាប់នឹងច្រាំងទន្លេសាប។ បុរសនោះមិនបានលាក់ចំណេះសម្រាប់តែខ្លួនគាត់ទេ ផ្ទុយទៅវិញគាត់បានចាប់ផ្តើមបង្រៀនអ្នកជិតខាង និងសាច់ញាតិអំពីអាថ៌កំបាំងនៃការងារប្រាក់និងស្ពាន់ របៀបធ្វើ ឆ្លាក់លំនាំ និងបង្កើតភាពស្រស់ស្អាតពីវត្ថុធាតុដើម។ យូរៗទៅ ជំនាញនេះបានក្លាយជាប្រពៃណី ពីមួយគ្រួសារ ទៅមួយគ្រួសារ។ ភូមិទាំងមូលបានយកសិប្បកម្មនេះធ្វើជាមុខរបរ រហូតធ្វើឱ្យកំពង់ហ្លួងត្រូវបានគេស្គាល់ថាជាភូមិប្រាក់ និងស្ពាន់ រហូតមក។

ប៉ុន្តែ សព្វថ្ងៃ មុខរបរនេះកំពុងដាំក្បាលចុះ ហើយឈានទៅប្រឈមនឹងអនាគតមួយដែលពោរពេញដោយភាពស្រពេចស្រពិល។

អ្នកស្រី ជុំ ធីតា ដែលជាប្អូនស្រីរបស់អ្នកស្រី ជុំ បុប្ផា មានប្រសាសន៍ថា សិប្បកម្មនេះបានធ្លាក់ចុះខ្លាំងនៅពេលមានផ្ទុះការរាតត្បាតជំងឺកូវីដ-១៩ ហើយចាប់តាំងពីពេលនោះមក មិនសូវមានទេសចរមកទស្សនាភូមិទេ ដែលធ្វើឱ្យចំណូលធ្លាក់ចុះ ហើយអ្នកស្រុកជាច្រើនបង្ខំចិត្តបោះបង់មុខរបរប្រពៃណីមួយនេះ ទៅធ្វើការរោងចក្រវិញដើម្បីរកលុយមកដោះបំណុលមីក្រូហិរញ្ញវត្ថុ។



*អ្នកស្រី ជុំ ធីតា កំពុងឆ្លាក់ចម្លាក់លើផ្ទិល។ រូបភាពដោយ៖ ជា សុខហេង*

អ្នកស្រីបានបន្ថែមទៀតថា “ការខ្សត់ខ្សោយនៃវត្ថុធាតុដើម ជាបញ្ហាធំមួយទៀត ខុសពីមុន ជំនាន់ខ្ញុំនៅក្មេងៗកាន់តែកញ្ច្រែងមួយទៅមាត់ទន្លេក៏រែងបានប្រាក់យកមកលក់បានលុយដែរ”។ ប៉ុន្តែបច្ចុប្បន្នវត្ថុធាតុដើម ប្រាក់និងស្ពាន់ខ្លះត្រូវទិញពីសិប្បកម្មនៅភូមិផ្សេង ឬនាំចូលពីក្រៅប្រទេស មកផលិត ធ្វើឱ្យចំណាយថ្លៃដើមកាន់តែខ្ពស់ ផលិតផលសម្រេចកាន់តែថ្លៃ ពិបាកលក់។

សម្រាប់ក្មេងៗជំនាន់ក្រោយ គឺភាគច្រើនបំផុតនាំគ្នាចាប់មុខរបរផ្សេង ហើយសឹងតែគ្មានអ្នកណាចាប់អារម្មណ៍ជាមួយសិប្បកម្មមួយនេះទេ ដោយសារវាមានបញ្ហាប្រឈមច្រើនពេក ហើយពិបាកទ្រាំជាមួយ។ ក្នុងនោះមានលោក សន ដារ៉ាណុច នៅភូមិពោធ៍តូចម្នាក់ដែរ។ យុវជនវ័យ ២០ឆ្នាំ រូបនេះ ដែលជានិស្សិតផ្នែកធនាគារនិងហិរញ្ញវត្ថុ និយាយដូច្នេះថា៖ “សម្រាប់ខ្ញុំ ខ្ញុំមិនចង់បន្តនូវមុខរបរគ្រួសារដែលធ្វើសិប្បកម្មប្រាក់នេះទេ ព្រោះ ការងារនេះហត់ ប្រើពេលវេលានិងកម្លាំងច្រើនក្នុងការផលិត ហើយទីផ្សារតម្លៃចង្អៀតពិបាកលក់ចេញ”។

តាមការរៀបរាប់ពន្យល់របស់សិប្បករ ដំណើរការផលិតគ្រឿងប្រាក់តាមបែបបុរាណនេះចាប់ផ្តើមដំបូងពីការជ្រើសរើសប្រាក់ឬស្ពាន់យកមកសំអាត មុននឹងយកវាទៅរំលាយដោយដុតកម្តៅ បន្ទាប់មកចាក់ចូលទៅក្នុងពុម្ពដែកដើម្បីបង្កើតជារូបរាងវត្ថុ។ បន្ទាប់មកទៀត គេប្រើជ័រឈើម៉្យាងដែលមានប្រភពនៅភ្នំគូលេនទៅកិនឱ្យម៉ដ្ឋ ហើយរំលាយក្លាយជាល្បាយ រួចចាក់ចូលទៅក្នុងរូបរាងឧបករណ៍ប្រាក់ឬស្ពាន់នោះ រួចហើយទុកឱ្យជ័រនោះរឹង ទើបគេអាចចាប់ផ្តើមដាប់និងឆ្លាក់ក្បាច់លើនោះបាន។

បន្ទាប់ពីបានទ្រង់ទ្រាយ សិប្បករចាប់ផ្តើមឆ្លាក់លំនាំលើផ្ទៃប្រាក់ឬស្ពាន់ដោយដៃ។ ដំបូងត្រូវគូរជាគំរូក្បាច់រចនាផ្សេងៗលើផ្ទៃប្រាក់ឬស្ពាន់ជាមុនសិន ទើបប្រើដែកឆ្លាក់មកដាប់តាមពីលើនោះ ដោយប្រើញញួរ និងដែកឆ្លាក់ដែលមានរាងដូចដែកគោល និងមានមុខក្បាច់ខុសៗគ្នាដើម្បីឆ្លាក់។

ជាចុងក្រោយ គេត្រូវធ្វើការច្រាសប្រាក់ឬស្ពាន់នោះឱ្យភ្លឺ និងប្រើសារធាតុធម្មជាតិ “ប្រេងត្រី” លាបពីលើទើបរួចរាល់។ ផលិតផលសម្រេចនីមួយៗមានសម្រស់គួរឱ្យភ្ញាក់ផ្អើល ព្រោះដុំនីមួយៗភ្លឺចែងចាំងដោយពន្លឺពណ៌ប្រាក់ ហើយមានការរចនាចាប់ពីរូបសត្វដូចជា សត្វដំរី សត្វស្លាប អណ្តើក រហូតដល់ចាន ពែង ប្រអប់ និងថាសដែលមានលំនាំយ៉ាងល្អិតល្អន់។ ចម្លាក់ខ្លះបានបង្ហាញពីវប្បធម៌ ប្រពៃណីខ្មែរដូចជាប្រាសាទអង្គរវត្ត ឬរបាំ ខណៈដែលចម្លាក់ខ្លះទៀតបង្ហាញពីទេវកថា និងលំនាំផ្កាជាដើម។ វត្ថុនីមួយៗអាចចំណាយពេលច្រើនថ្ងៃ ឬច្រើនសប្តាហ៍ដើម្បីបញ្ចប់ ហើយពេលខ្លះអាចឈានចូលដល់រាប់ខែក៏មានដែរ។

អ្នកស្រី ជុំ ធីតា មានប្រសាសន៍ថា៖ “កាងារនេះត្រូវការភាពអត់ធ្មត់ខ្លាំងណាស់ទើបធ្វើបាន ហើយទំរាំចេញជារូបរាងមួយៗត្រូវឆ្លងកាត់ដំណាក់កាលជាច្រើននិងពេលវេលាយូរ”។



រូបគាត់ និងបងស្រីរបស់គាត់ គឺ អ្នកស្រី ជុំ បុប្ផា ស្ថិតក្នុងចំណោមមនុស្សភាគតិចនៅក្នុងភូមិ ដែលកំពុងទ្រាំទ្រជាមួយអាជីវកម្មនេះ បើទោះជាពិបាករកកម្រៃចិញ្ចឹមសម្រាប់ផ្គត់ផ្គង់ជីវភាពក៏ដោយ ប៉ុន្តែដើម្បីបុព្វហេតុថែរក្សាសិល្បៈមួយបែបដែលជាអត្តសញ្ញាណវប្បធម៌ជាតិអស់ជាច្រើនជំនាន់មកហើយ ឱ្យនៅរស់រានបន្តទៅទៀត។

ដៃដាប់បណ្តើរ មាត់និយាយបណ្តើរ អ្នកស្រី ជុំ បុផ្ផា បានអំពាវនាវឱ្យក្រសួងពាក់ព័ន្ធ ជួយផ្សព្វផ្សាយអំពីសិប្បកម្មសិល្បៈចម្លាក់ដោយដៃនេះ និង “សូមជួយជំរុញឱ្យមានភ្ញៀវទេសចរមកលេងភូមិនេះឱ្យកាន់តែច្រើន ព្រោះជាកន្លែងដែលដូនតាយើងចាប់ផ្តើមដំបូងគេ ហើយខ្ញុំមិនចង់ឃើញសិប្បកម្មដែលបានបន្សល់ទុកពីដូនតាត្រូវបាត់បង់នោះទេ”៕



*លោក លី សុខម៉េង កំពុងផ្ទង់ស្មារតីទៅលើកីតម្បាញ។ រូបភាពដោយ៖ ស៊ីម សុភ័ត្រា*

# នៅស្រុកបាទី មុខរបរតម្បាញហូលខ្មែរសម្លឹងទៅអនាគតដែលគ្មានអ្នកបន្តវេន

***ដោយ ស៊ីម សុភ័ត្រា និង ស៊ាងលី លីហួយ***

**តាកែវ -** សូរកីតម្បាញដែលធ្លាប់តែលាន់ផ្ទងផាំងទ្រហឹងក្នុងភូមិខ្នាររោង ឃុំពារាម ស្រុកបាទី ខេត្តតាកែវ ហាក់ដូចជាមានសភាពស្ងាត់ជាងមុន។ នៅតាមផ្ទះជាច្រើន កីត្រូវបានគេគ្របទុកចោលគ្មានមនុស្សកាន់។ នៅក្រោមផ្ទះ លោក លី សុខម៉េង កំពុងផ្ទង់ស្មារតីទៅលើកីតម្បាញ ហើយនិយាយថាគាត់ប្រហែលជាមនុស្សជំនាន់ចុងក្រោយហើយដែលប្រកបមុខរបរត្បាញហូលនៅក្នុងភូមិរបស់គាត់។

“អស់ពីជំនាន់ពួកខ្ញុំទៅ មិនដឹងមានអ្នកណាមកបន្តមុខរបរត្បាញហូលនេះទៀតទេ ក្មេងៗជំនាន់ក្រោយនេះបើមិនរៀនត នាំគ្នាចូលរោងចក្រអស់ បើអញ្ចឹងហូលខ្មែរដែលជារបរពីដូនតានេះនឹងទៅជាយ៉ាងណា?” - លោក លី សុខម៉េង អាយុ ៤៦ឆ្នាំ និយាយបណ្ដើរដៃត្បាញបណ្ដើរ។

មិនមែនតែគាត់ម្នាក់ឯងទេដែលគិតដូច្នេះ។ អ្នកស្រុកជាច្រើននៅក្នុងឃុំពារាម បានសម្ដែងក្ដីបារម្ភដូចគ្នា នៅពេលដែលអាជីវកម្មត្បាញហូលកំពុងពិបាកប្រជែងជាមួយផលិតផលហូលនាំចូល ស្របពេលក្មេងៗជំនាន់ក្រោយជ្រើសរើសទៅធ្វើការនៅរោងចក្រកាត់ដេរវិញ ជាជាងអង្គុយត្បាញដែលត្រូវការចំណាយពេលយូរ ហើយទទួលបានកម្រៃតិច។

បាទីជាស្រុកមួយក្នុងខេត្តតាកែវដែលមានភាពល្បីល្បាញខាងវិស័យវាយនភណ្ឌតម្បាញហូល-ផាមួង។ វាជាមុខរបរមួយរបស់ប្រជាពលរដ្ឋស្ទើរតែគ្រប់ផ្ទះសម្រាប់ចិញ្ចឹមជីវិតអស់ជាច្រើនជំនាន់តមក។ ប៉ុន្តែ ក្នុងប៉ុន្មានឆ្នាំចុងក្រោយ របរនេះត្រូវបានសង្កេតឃើញថាមានការធ្លាក់ចុះ ដែលបណ្ដាលមកពីការផ្លាស់ប្ដូរជម្រើសការងារការប្រកួតប្រជែងពីហូលនាំចូល និងកត្តាសេដ្ឋកិច្ចជាដើម។

របាយការណ៍ស្ដីពីទិន្នន័យមុខរបរសិប្បកម្មដោយដៃរបស់រដ្ឋបាលស្រុកបាទី នៅក្នុងឆ្នាំ២០២៥នេះ បានបង្ហាញថា តម្បាញហូលសរុបមាននៅសល់ចំនួន ១០២១កី តែប៉ុណ្ណោះដែលមានទីតាំងស្ថិតនៅក្នុងឃុំពារាម ឃុំចំបក់ ឃុំត្នោត និង ឃុំដូង។

លោក វង់ វិន មេភូមិខ្នាររោង និយាយថា កាលពី ៤ ទៅ ៥ឆ្នាំមុនតាមផ្ទះនីមួយៗក្នុងភូមិ មាន ២ ទៅ ៣កី ប៉ុន្តែដោយសារសេដ្ឋកិច្ចធ្លាក់ចុះសម័យកូវីដ ហូលធ្លាក់ថ្លៃ ចំពេលមានរោងចក្របើកច្រើននៅក្នុងខេត្ត អ្នកតម្បាញនាំគ្នាឈប់ ហើយទៅធ្វើការនៅរោងចក្រវិញ។ លោកអ៊ំបន្តថា៖ “កាលពីមុនកូវីដ-១៩ នៅក្នុងភូមិខ្នាររោង អ្នកធ្វើហូលមានជិត ២០០ គ្រួសារតែឥឡូវនេះសល់តែ ៦៣ គ្រួសារទេ ដែលនៅប្រកបរបរតម្បាញហូលនេះ”។



*លោកអ៊ំ ឆឹល ចាន់ អាយុ 50 ឆ្នាំ កំពុងត្បាញហូលនៅខាងមុខផ្ទះ។ រូបភាពដោយ៖ ស៊ឹម សុភ័ក្រ្តា*

### ***ចំណាយពេលយូរ បានលុយតិច***

ទម្រាំនឹងបានហូលមួយក្បិនដែលមានប្រវែង ៤ម៉ែត្រ ទទឹង ១ម៉ែត្រ អ្នកត្បាញត្រូវមានការអត់ធ្មត់ខ្លាំង ហើយចំណាយពេលជាមធ្យមពី ៦ ទៅ ១០ថ្ងៃ។

ក្នុងវ័យ ៥០ឆ្នាំ លោក ឆឹល ចាន់ រៀនចេះត្បាញពីភិរិយារបស់គាត់កាលពី៣០ឆ្នាំមុន។ បច្ចុប្បន្ន គាត់ជាអ្នកតម្បាញដ៏ប៉ិនប្រសប់ រហ័សរហួន និងស្ទិតស្ទាញម្នាក់ដែលត្បាញហូលបានមួយសំពត់តែក្នុងរយៈពេលបួនថ្ងៃប៉ុណ្ណោះ រាល់ថ្ងៃលោកចាប់ផ្ដើមត្បាញពីម៉ោង ៦កន្លះព្រឹក ដល់ម៉ោង៧យប់។ គាត់មានប្រសាសន៍ថា៖ “ក្នុងនាមជាអ្នកត្បាញហូល ពូចង់ឱ្យហូលបានឡើងថ្លៃជាងមុន កាលណាបានថ្លៃសល់កម្រៃខ្លះ។ ឥឡូវនេះធ្វើបានត្រឹមមួយចាយៗ ម្ហូបអាហារបាយទឹក កូនចាយខ្លះៗ រកសល់គ្មានទេ គឺអត់តែម្ដង។ បានធ្វើស្រែទប់ទល់ខ្លះកុំអីគ្មានអង្ករទេក្មួយ”។

អ្នកស្រី នាង សុភី វ័យ៤០ឆ្នាំ ដែលចេះត្បាញជាង ២០ឆ្នាំមកហើយ មានប្រសាសន៍ថា៖ “ហូលនៅលក់ដាច់ធម្មតា ថៅកែយកដឹងតែបានលុយ គ្រាន់តែធ្លាក់ថ្លៃពីមុនធ្លាប់បានតម្លៃ ពី៥០ម៉ឺនរៀល ទៅ ៦០ម៉ឺនរៀល ឥឡូវបានត្រឹមតែ ៤៥ ម៉ឺនរៀល តាមម៉ូតដែរ ម៉ូតខ្លះបាន ៥០ម៉ឺនរៀល ទៅ សាច់ចំណេញខ្ទង់ ២០ម៉ឺនរៀល”។ អ្នកស្រីពោលបន្តថា សម្រាប់អ្នកប្រើប្រាស់ បច្ចុប្បន្នគេនិយមប្រើហូលនាំចូលពីប្រទេសក្រៅដូចជាថៃ ជប៉ុន បារាំង ជាងព្រោះតម្លៃវាថោក។

បញ្ហាមួយទៀត ដែលអ្នកផលិតហូលក្នុងស្រុកពិបាកប្រជែងជាមួយហូលនាំចូលពីក្រៅប្រទេសគឺ តម្លៃ និងគុណភាពរបស់សរសៃសូត្រ ដែលជាវត្ថុធាតុដើមសម្រាប់ការត្បាញ។

នៅតាមផ្លូវលំតូចៗក្នុងឃុំពារាម នៅសល់ដើមមនខ្លះៗដុះក្បែររបងផ្ទះ។ កាលពីមុនអ្នកស្រុកបានដាំមន ចិញ្ចឹមដង្កូវនាង ដើម្បីផលិតចេញជាសសៃរសូត្រដោយខ្លួនឯងផ្ទាល់។ ប៉ុន្តែបច្ចុប្បន្ននេះសឹងតែគ្មានអ្នកស្រុកណាដាំមន ចិញ្ចឹមដង្កូវនាង សម្រាប់ធ្វើសូត្រទៀតទេ។ សិប្បករតម្បាញហូលនៅក្នុងភូមិបានឱ្យដឹងថា សរសៃរសូត្រដែលនៅលើកីតម្បាញរបស់ពួកគេសព្វថ្ងៃនេះ គឺសុទ្ធតែជាសូត្រដែលនាំចូលពីវៀតណាម ព្រោះការផលិតសូត្រក្នុងស្រុកតាមរយៈការចិញ្ចឹមដង្កូវនាង មានការលំបាក ត្រូវការចំណាយពេលច្រើន ហើយលទ្ធផលចេញមកមិនស្អាតដូចសរសៃសូត្រដែលនាំចូលនោះទេ។

លោក ម៉ូ ឆើត វ័យ ៤២ឆ្នាំ រស់នៅក្នុងស្រុកបាទីខេត្តតាកែវ ដែលជាឈ្មួញកណ្ដាល យកហូលទៅលក់បន្តនៅទីក្រុងភ្នំពេញបាននិយាយថា ក្នុងមួយសប្ដាហ៍លោកប្រមូលហូលពីអ្នកត្បាញនៅក្នុងភូមិបានប្រហែលជា២០០ក្បិន តិចជាងពាក់កណ្ដាលកាលនៅមុនពេលមានជំងឺកូវីដ-១៩។ កាលនោះ គាត់អាចប្រមូលទិញបានពី ៤០០ ទៅ៥០០ក្បិន ក្នុងមួយសប្ដាហ៍ សម្រាប់យកទៅលក់បន្ត។ គាត់មានប្រសាសន៍ថា៖ “ម៉ូយអ្នកត្បាញហូលឱ្យពូពីមុនមានច្រើន ប៉ុន្តែដោយសារហូលវាចុះថោក គេឈប់ត្បាញ នាំគ្នាចូលរោងចក្រអស់ហើយ”។

### ***អ្នកប្រើប្រាស់ពុំសូវមានលុយ***

ទ្រឹស្ដីនៅក្នុងអាជីវកម្មតែងនិយាយថា អតិថិជនជាចៅហ្វាយនាយ។ ដូចគ្នាសម្រាប់មុខទំនិញទូទៅដែរ តម្លៃដើរតួសំខាន់នៅលើការសម្រេចចិត្តរបស់អ្នកទិញហូលយកទៅប្រើប្រាស់។

អ្នកស្រី អ៊ិន សុខា អាយុ ៤៩ឆ្នាំ ជាគ្រូបង្រៀនបឋមសិក្សា និងជាអ្នកធ្លាប់ប្រើប្រាស់ហូលខ្មែរ បច្ចុប្បន្នស្ថិតក្នុងចំណោមស្ត្រីខ្មែរដែលងាកទៅទិញហូលនាំចូលពីក្រៅមកធ្វើសំពត់ស្លៀកវិញ។ អ្នកស្រីមានប្រសាសន៍ថា៖ “រាល់ថ្ងៃខ្ញុំ និងគ្រូៗផ្សេងទៀតភាគច្រើន គឺប្រើប្រាស់ហូលអ៊ីតាលី ឬហូលបារាំងជំនួសហូលខ្មែរ ព្រោះតម្លៃថោកសមរម្យ អ៊ុត បោកទឹកបានដោយសេរី ចំណែកហូលខ្មែរបោកទឹកមិនបាន ត្រូវយកឱ្យគេបោក ហើយបើបោកច្រើនដងអាចខូចទម្រង់មិនដូចដើមទេ”។

អ្នកស្រីបន្តថា មិនមែនអ្នកស្រីមិនចង់ប្រើប្រាស់ហូលខ្មែរទេ ប៉ុន្តែដោយសារតម្លៃថ្លៃជាង ១០០ ដុល្លារ ឯណោះ មានតម្រូវការបុណ្យទានផ្ទាល់ខ្លួនទើបអាចទិញប្រើយូរៗម្ដង។ សម្រាប់ការប្រើប្រាស់រាល់ថ្ងៃ គឺមានតែហូលអ៊ីតាលី ឬហូលបារាំង ដែលស្រួលប្រើ និងស័ក្តិសមនឹងសមត្ថភាពថវិកា។

អាជីវករលក់ហូលក្នុងផ្សារអូឡាំពិកវិញភាគច្រើនបានបញ្ចេញមតិស្រដៀងគ្នានឹងអ្នកគ្រូដែរ។ សព្វថ្ងៃ ហូលដែលត្បាញក្នុងស្រុកពុំសូវមានអ្នកនិយមប្រើខ្លាំងដូចកាលពីមុនឡើយ ចាប់តាំងពី

សម័យកូវីដ-១៩មក ឯតម្លៃរបស់វាក៏ធ្លាក់ចុះផងដែរ។ ជាមួយគ្នានេះក្នុងរយៈពេល៤ទៅ៥ឆ្នាំចុងក្រោយ ការជ្រៀតចូលនៃហូលបរទេសក៏ជាកត្តាចម្បងមួយដែលគំរាមកំហែងដល់ទីផ្សារហូលខ្មែរ។ ហូលនាំចូលពីបរទេសមានតម្លៃត្រឹមតែ ៦ម៉ឺន ទៅ ៨ម៉ឺនរៀល ប៉ុណ្ណោះ ប៉ុន្តែហូលខ្មែរមានតម្លៃលើសនេះ១០ដង ដែលធ្វើឱ្យអ្នកមានលទ្ធភាពមធ្យមញញើតទិញ ហើយងាកមកប្រើហូលនាំចូលពីក្រៅវិញ។

ទោះជាយ៉ាងណាហូលខ្មែរដែលមានទឹកដៃល្អ រំលេចដោយគោម ឬក្រឡារចនាក្បាច់ក្បូរនៅតែទទួលបានតម្លៃថ្លៃ និងនៅតែមានអ្នកគាំទ្រ ជាពិសេសអ្នកមានធូរធារ។

## ***អ្នកណានឹងបន្តវេន?***

ជាមួយទឹកមុខញញឹម អ្នកស្រី វង់ ម៉ាលី វ័យ៤៨ឆ្នាំ កំពុងត្បាញហូលដែលជាមុខរបរគាត់បានធ្វើអស់រយៈពេល៣៣ឆ្នាំមកហើយ បន្តពីម្ដាយរបស់គាត់ដែលចេះតៗពីដូនតាមក។ លោកស្រីមានប្រសាសន៍ថា របរនេះត្រូវការភាពអំណត់ព្រោះទម្រាំត្បាញបាន១តឹកៗគឺត្រូវការពេលយូរ។ សម្រាប់ហូលមួយក្បិន គាត់ត្រូវចំណាយពេលប្រហែលជាមួយអាទិត្យ។ កាលមុនហូល១ក្បិន គាត់អាចលក់បាន ពី៦០ ទៅ៨០ម៉ឺនរៀល តាមប្រភេទហូល ប៉ុន្តែឥឡូវនេះបានត្រឹមតែ៤០ ទៅ ៥០ម៉ឺនរៀល ប៉ុណ្ណោះ ហើយបើគិតថ្លៃចំណេញគឺខ្វះ១០ម៉ឺនរៀល ផ្ទុយពីមុនដែលយ៉ាងហោចណាស់ចំណេញបាន២០ម៉ឺនរៀល ជាង។

លោកស្រីបានរំឭកឱ្យដឹងថា៖ "នៅម្ដុំនេះ ពីមុនសម្បូរសហគមន៍អ្នកតម្បាញ ម៉ោង៩យប់ក៏គេនៅជុំគ្នាធ្វើឮសូរផ្ទួងផាំងគ្មានបានដេកពួនទេ ប៉ុន្តែឥឡូវនេះលែងមានគេធ្វើជាសហគមន៍ហើយ ភាគច្រើនដូរទៅធ្វើរោងចក្រឬក៏ត្បាញតាមផ្ទះខ្លួនវិញ"។

លោកស្រី នាង សុភី មានប្រសាសន៍ថា ការងារត្បាញនៅផ្ទះស្រួលជាងធ្វើការរោងចក្រ អាចមានពេលសម្រាកហើយធ្វើបាយទឹក មិនដូចធ្វើការរោងចក្រដែលមានគេកំណត់ម៉ោងម៉ឺងម៉ាត់។ អ្នកស្រីពោលបន្ថែមទៀតថា កូនស្រីរបស់គាត់ដែលកំពុងរៀននៅថ្នាក់អនុវិទ្យាល័យ តែងតែឆ្លៀតមកជួយត្បាញនៅពេលដែលទំនេរពីការសិក្សា ប៉ុន្តែបានបញ្ជាក់ប្រាប់ថាគេនឹងមិនប្រកបរបរនេះតពីអ្នកស្រីឡើយ។

លោក លី សុខម៉េង ធ្លាប់សួរបែបលេងសើចទៅកាន់កូនស្រីដែលកំពុងរៀនថ្នាក់ទី១១ថា៖ "កូនឯងម៉េចៗអីត្បាញទៅ កូនឆ្លើយមកវិញថាអត់ទេ"។ ដៃកំពុងត្បាញ គាត់ពោលបន្ថែមថា៖ "អស់ពីជំនាន់ពួកខ្ញុំទៅ មិនដឹងមានអ្នកណាមកបន្តមុខរបរត្បាញហូលនេះទៀតទេ ក្មេងៗជំនាន់ក្រោយនេះបើមិនរៀនត បើអញ្ចឹងហូលខ្មែរដែលជារបរពីដូនតានេះនឹងទៅជាយ៉ាងណា?"



*ស្ត្រីម្នាក់ក្នុង ឃុំពារាម កំពុងត្បាញហូលនៅខាងមុខផ្ទះ។។ រូបភាពដោយ៖ ស៊ីម សុភ័ត្រា*



*Rescued cats rest on the staircase inside Cate Café. Photo by Catera Cafe team*

# Cat Café: A Place Where Stray Cats Get a Second Chance at Life

***By Nan Meng Hor and Touch Soranya***

**Phnom Penh –** In a quiet afternoon, sunlight spills into the see-through door of Catera Cambodia, where young Cambodians sip latte and snap photos of sleeping cats cuddled on the cushions. For these visitors, a cat café is more than a trendy spot for coffee or drinks; it is a space of comfort, relax, and connection. But for the cats, it's their second chance.

In recent years, cat cafés have sprung up in Cambodia, especially in urban areas like Phnom Penh and Siem Reap. At first glance, the concept of café shop with cats may seem simple and even playful, but beneath the surface is a great purpose in Cambodia's growing movement for animal welfare.

"It's not a profit-making business. However, it's a money losing business," says Cathy Leong, founder of Catera Cambodia, a cat café located at number 36B, Street 456, in Toul Tumpoung area, Phnom Penh.

Ms. Leong, a native of Guangdong province of China, came to Cambodia in 2017 to look for work. She started to rescue cats during the COVID pandemic, when many of them were struggling to find food from the streets. As a former real estate employee, she had never managed a business before, let alone one filled with animals, until she opened this café in 2022. "I had no experience in cafes, food and beverage, or opening a shop by myself. So, everything, I started from zero," she said.

Finding a spot was one of her big challenges. Many landlords rejected her as soon as they learned that the café would shelter animals. "Many of the locals don't want to have their spaces for animals," Ms. Leong said, adding that it took her months to find a space that was not only available but also willing to accept her vision.



Trim Nita, a customer, play with a cat at Catera Café. Photo by: Touch Soranya

***Adopt, don't shop***

For many young people, the cat cafés in the city become a space of emotional comfort and connection. The cozy atmosphere, combined with the quiet presence of animals, offers a unique environment that feels different from the usual café experience.

"I find that spending time with cats in a place like that reduces my stress level a lot because by observing how each cat behaves or even playing with them brings me a sense of peace," said Diner Chharaneed, a 20-year-old university student.

Long Vireakchet, a 20-year-old stylist and a regular patron of the cat café, said he was drawn to it by "a different type of love that can't come from anywhere else."

"The vibe at the cat café calms me down a lot, and I love spending time with cats and playing with them. All animals deserve a chance, and all they need is love and patience. After all, animals need us just as much as we need them," Vichet said.

Since she started to rescue the cats, Ms. Leong has rescued over 355 cats. Some of them have been adopted, some are under foster care, some simply passed away, but many are still roaming around in her place.

While the idea of a cat café might sound fanciful, some establishments are taking their mission much further by working closely with rescue groups in a city where animal welfare was frequently overlooked.

Yama Doungchanpisey said she finds cat café a very smart and entertaining concept for cat lovers like herself. One of the cat cafés she visits the most is Ministry of Cat, also located in the Toul Tumpoung area in Phnom Penh. It is the first cat café-and-rescue center in Cambodia which was opened in 2018. A few visits led her to adopt a pair of cats that were bother and sister.

"It clearly takes a lot of dedication to manage a cafe while looking after so many cats at the same time," she said of the efforts made by the café owners in maintaining cleanliness, odor control, and proper care of the animals.

She added that adopting a cat is not just giving that animal a chance at a loving, healthy life, but it is about creating space in shelters for another stray animal who urgently needs care. "I fully oppose buying animals. So, if anyone wants a cat, just adopt, don't shop," she suggested.

At Phnom Penh Animal Welfare Society (PPAWS), Laura Callan, a practice manager from the United Kingdom, agreed that adoption is a better option for cat lovers. She noted that there's a growing number of cat cafés working with local rescue organizations to help cats recover and find loving homes. She also recounted a touching story of the recovery of a cat that almost lost its life when it was stuck inside a car engine.

"She was inside the car engine, and the owner of the car didn't notice the presence of the cat, then they turned on the engine. And the cat was badly injured, so we had to have her leg amputated," Ms. Callan said. "Now, she is in her recovery stage, and when she is fully recovered, we will be able to find a home for her."

Having previously worked with animals in the UK, Ms. Callan said the number of pets in need of help is overwhelming and encouraged the public to support cats in small ways like offering food, safe shelter, and, most importantly, desexing to control overpopulation.

"A male and female cats can create 40,000 kittens in a few years, and if the numbers keep growing, many more cats will also be suffering on the street without shelter," she said.

Tauchpich Bunlim, an 18-year-old university student, said that her perspective about animal welfare has changed after several visits to cat cafés and that rescuing and adopting are "the best solution in helping them."

As the sun begins to set, a group of students gathers around an orange and white cat named Zai zai at the Catera Cambodia. One girl gently brushed his fur while sipping her matcha latte. Another takes photos with the other cats. A boy reads quietly beside them. There's laughter, calm, and connection – comforting moments mutually offered by both the visitors and their furry companions.

While regular cafés offer her a comfortable space and drink, Ms. Bunlim said she would still prefer cat café, because "a person who comes to buy a drink can help almost 10 cats already."




*On the wall inside Cat Café, a board is filled with pictures of rescued cats waiting to move to a permanent home. Photo by Touch Soranya*

# ផលិតដោយ

ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



អាសយដ្ឋាន៖ អគារ DMC/CCI នៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, មហាវិថីសហព័ន្ធរុស្ស៊ី, ខណ្ឌទួលគោក, រាជធានីភ្នំពេញ
លេខទូរស័ព្ទ៖ (+855) 23 88 44 08
អ៊ីម៉ែល៖ admin@dmc-cci.edu.kh
គេហទំព័រ៖ www.dmc-cci.edu.kh